ស.ផ.ក.ក.
COSECAM

# COSECAM



# ផលប៉ះពាល់នៃការបិទតំបន់ស្វាយប៉ាក

## ការសិក្សាស្ដីពីការជួយអន្តរាគមន៍របស់ប៉ូលីស
## និងអង្គការអន្តរជាតិនៅតំបន់ស្វាយប៉ាក

របាយការណ៍ដោយ
Dr. Frédéric Thomas

មករា ២០០៥

# មាតិកា


សេចក្តីថ្លែងអំពីបញ្ហា ---------------------------------------- ១

១- លំនាំដើម ---------------------------------------- ៣

២- ប្រវត្តិ ---------------------------------------- ៣

៣- គោលដៅនៃការសិក្សា ---------------------------------------- ៤

៤- គោលបំណងនៃការស្រាវជ្រាវ ---------------------------------------- ៤

៥- ប្រវត្តិភូមិ ---------------------------------------- ៥

៥.១ ការពិពណ៌នាភូមិ និងប្រជាជន ---------------------------------------- ៥

៥.២ សកម្មភាពសេដ្ឋកិច្ច និងសង្គម ---------------------------------------- ៦

៥.៣ ពេស្យាចារ និងការវិវត្តន៏ ( ចំនួនលក្ខណៈធម្មជាតិ និងអាកប្បកិរិយា) -------------- ៧

៦- ប្រវត្តិអង្គការក្រៅរដ្ឋាភិបាលក្នុងតំបន់ស្វាយប៉ាក ---------------------------------------- ៩

៦.១ ការផ្តត់ផ្គង់នៃការការពារ ---------------------------------------- ១០

៦.២ សកម្មភាពទប់ស្កាត់ និងសង្គ្រោះ ---------------------------------------- ១៣

៦.៣ ការស្ទង់មតិ ---------------------------------------- ១៤

៧- ប្រសិទ្ធផល និងផលប៉ះពាល់នៃកម្មវិធីរបស់រដ្ឋាភិបាល និងអង្គរការក្រៅរដ្ឋាភិបាលស្តីពីបញ្ហា ស្ទុគ្រស្នាញ និងអំពើពេស្យាចារក្នុងតំបន់ស្វាយប៉ាក ---------------------------------------- ១៥

៧.១ ការប៉ាន់ប្រមាណនៃផលប៉ះពាល់ពីការឆ្មក់ចូលផ្ទះបនស្តីពី បណ្តាញពេស្យាចារ និងជួញដូរក្នុងតំបន់ស្វាយបាក[១] ---------------------------------------- ១៧

៧.២ ការប៉ាន់ប្រមាណលើផលប៉ះពាល់នៃការឆ្មក់ចូលផ្ទះបន ស្តីពីការរីករាលដាលនៃតួអង្គ ពេស្យាចារពីតំបន់ស្វាយប៉ាក និងផលវិបាករបស់វាចំពោះអ្នករកស៊ីផ្លូវភេទ ---------- ២១

៧.៣ ការប៉ាន់ប្រមាណលើផលប៉ះពាល់នៃឆ្មក់ចូល និងការបិទផ្ទះបនស្តីពី ជីវិតអ្នក សហគមន៏ក្នុងតំបន់ស្វាយប៉ាក ---------------------------------------- ២៣

៧.៤ ការប៉ាន់ប្រមាណនៃឥទ្ធិពលលើការឆ្មក់ចូលស្តីពីសកម្មភាព សុខមាលភាពសង្គម និងសហគមន៏ដោយអង្គការក្រៅ រដ្ឋាភិបាលផ្សេងៗ ------------------------ ២៧

៨- ការសន្និដ្ឋាន និងស្ថានភាពនៃតំបន់ស្វាយប៉ាកក្នុង ខែមករា ឆ្នាំ ២០០៥------------------------ ២៨


[១] យើងគ្រាន់តែជជែកអំពីតំបន់ស្វាយប៉ាកនៅទីនេះ ហើយដែលមានតំបន់ភ្លើងពណ៌ក្រហមជាច្រើនផ្សេងៗទៀតក្នុងក្រុងភ្នំពេញដែលការឆ្មក់ចូល និងសង្គ្រោះត្រូវបានធ្វើឡើងផងដែរ ។

៩-  អនុសាសន៍ ------------------------------------------------------------ ៣០
ឧបសម្ព័ន្ធទី ១ ------------------------------------------------------------ ៣២
ឧបសម្ព័ន្ធទី ២ ------------------------------------------------------------ ៣៨

# សេចក្តីថ្លែងអំពីបញ្ហា

របាយការណ៍នេះ បង្ហាញនូវរបកគំហើញពីការស៊ើបអង្កេតដែលមានបំណងសិក្សាលើផលប៉ះពាល់វិជ្ជមាន ឬអវិជ្ជមាននៃការបិទនូវតំបន់ស្វាយប៉ាក ដែលជាតំបន់ពេស្យាចារស្ថិតនៅចម្ងាយ ១១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ។ របាយការណ៍នេះ មិនមានគោលបំណងរិះគន់លើអន្តរាគមន៍របស់នគរបាលនៅស្វាយប៉ាក ឬក៏ចង្អុលបង្ហាញអង្គការណាមួយនោះទេ ប៉ុន្តែមានគោលបំណងគូសបញ្ជាក់នូវរយៈពេលដ៏យូរដែលត្រូវការបិទតំបន់នេះឱ្យបានច្បាស់លាស់ ហើយនិងសេចក្តីត្រូវការនៃវិធីសាស្រ្តខុសប្លែកគ្នា និងត្រឹមត្រូវដោយអង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងាររដ្ឋាភិបាល និងអង្គភាពនគរបាល។ ទាំងរដ្ឋាភិបាល ទាំងអង្គការក្រៅរដ្ឋាភិបាលដែលប្រឆាំងនឹងការជួញដូរ គួរតែចាត់ទុកស្រ្តី/កុមារដែលរកស៊ីផ្លូវភេទថា ជាជនរងគ្រោះនៃដំណើរការអភិវឌ្ឍន៍អតុល្យភាពដែលជះឥទ្ធិពលជាលក្ខណៈអន្តរជាតិ។ ជាក់ស្តែងជនរងគ្រោះទាំងនេះភាគច្រើនកំពុងឆ្លើយតបទៅនឹងសម្ពាធគ្រួសារ ដែលជំរុញឱ្យធ្វើជាពេស្យាចារ។ ការអះអាងមួយផ្សេងទៀតជាបន្ទុករបស់រដ្ឋាភិបាល ដើម្បីប្រឹងប្រែងបន្ថែមលើបណ្តាញពេស្យាចារ ជាងប្រជាជនដែលរកស៊ីផ្លូវភេទ។ តាមពិតទៅអំពើពុករលួយ និងការពាក់ព័ន្ធរបស់មន្ត្រីដែលមានបុណ្យស័ក្តិខ្ពស់ ជាបញ្ហាពិត ដែលមានការពាក់ព័ន្ធក្នុងការសម្រេចគោលដៅនៃការបញ្ឈប់នូវការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរលើកុមារ។

សេចក្តីត្រូវការនៃដំណើរការដ៏ត្រឹមត្រូវ គឺដើម្បីធ្វើអោយប្រសើរឡើងនូវប្រសិទ្ធិផលនៃកម្មវិធីប្រឆាំងការជួញដូរ និងគោលនយោបាយពាក់ព័ន្ធដែលប្រសើរជាងមុន។ ឧទាហរណ៍ ការបិទដ៏ជោគជ័យនៃតំបន់ស្វាយប៉ាក មិនបានបញ្ឈប់នូវការកេងប្រវ័ញ្ចផ្លូវភេទ និងជំនួញផ្លូវភេទលើកុមារ និងក្មេងស្រីដែលរកស៊ីផ្លូវភេទក្នុងតំបន់ស្វាយប៉ាកពីមុនមកនោះទេ។ អាក្រក់ជាងនេះទៅទៀត ឬប្រហែលជាល្អជាងនេះសម្រាប់ពួកគេ យើងនឹងឃើញថា ជួនកាលចំនួនមនុស្សទាំងនេះនឹងរីករាលដាលទូទាំងប្រទេសដោយមានកម្រិតជីវភាពរស់នៅ និងស្ថានភាពការងារដែលយើងមានផែនការសិក្សាក្នុងរបាយការណ៍នេះ។ គោលនយោបាយមួយចំនួន ដែលមានគោលបំណងប្រយុទ្ធប្រឆាំងការជួញដូរមិនត្រូវបានតំរូវទៅតាមស្ថានភាពក្នុងស្រុក ហើយអង្គការក្រៅរដ្ឋាភិបាលមិនមានតួនាទីដើម្បីពង្រឹងនូវគំហើញរបស់ពួកគេក្នុងចំណោម និងតាមរយៈសារព័ត៌មាន ឬដើម្បីធានាមូលនិធិ ប៉ុន្តែគាំទ្រយ៉ាងសំខាន់ដល់ការអនុវត្តន៍ច្បាប់ និងផ្តល់ជំនួយដល់ជនរងគ្រោះ។

លើសពីនេះទៅទៀត យើងយល់ថាបញ្ហារពេស្យាកម្ម គឺជាបញ្ហាយ៉ាងសំខាន់មួយផងដែរសម្រាប់ហេតុផលជាច្រើន ហើយវាអាចជាប្រភពនៃការមិនឯកភាពគ្នាផងដែររវាងអង្គការក្រៅរដ្ឋាភិបាលក្នុងលក្ខខណ្ឌសកម្មភាពស្របច្បាប់។ វិវាទដំបូងទំនងជាភាពស្របច្បាប់នៃវិធានការរបស់អង្គការក្រៅរដ្ឋាភិបាល ដែលជាសំខាន់ក្នុងលក្ខខណ្ឌនៃការយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋ ដែលប្រព្រឹត្តអំពើខុសច្បាប់ ឬប្រជាពលរដ្ឋដែលកំពុងត្រូវបានគេជួញដូរ។ ប៉ុន្តែផ្នែកប្រឆាំងនឹងការជួញដូរ អង្គការក្រៅរដ្ឋាភិបាលនីមួយៗត្រូវតែធ្វើសេចក្តីសម្រេចថា តើពួកគេ

អាចដឹកនាំខ្លួនឯងក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលបានចំងាយប៉ុន្មាន ហើយមិនត្រូវអនុវត្តជាន់លើការងាររបស់រដ្ឋាភិបាលនោះទេ។ ការផ្តល់នូវសេវាសង្គមដោយអង្គការក្រៅរដ្ឋាភិបាល ក៏ជាអាទិភាពមួយផងដែរ ដើម្បីធានានូវសិទ្ធិកុមារនិងយុវជន ហើយដើម្បីទទួលបាននូវព័តិមានដ៏មានតម្លៃក្នុងការធានាដល់ជនអនាចារ ហើយជនដែលស្វែងរកព្រហ្មចារីត្រូវបាននាំយកទៅកាត់ទោស។ ភាពជាដៃគូរត្រូវតែបានបង្កើតឡើងរវាងនគរបាល អង្គការក្រៅរដ្ឋាភិបាល និងសេវាសង្គមមានសម្រាប់ការធ្វើអន្តរាគមន៍។ បច្ចុប្បន្ននេះអង្គការក្រៅរដ្ឋាភិបាលមួយចំនួនមានវិធីសាស្ត្រដ៏ល្អ ប៉ុន្តែអង្គការមួយចំនួនទៀតមិនមាន។ របាយការណ៍ នេះមានគោលបំណងជំរុញឱ្យវិធីសាស្ត្រដែលមានលក្ខណៈរួមដ៏ល្អក្នុងការជួយសង្គ្រោះជនរងគ្រោះ ហើយជៀសវាងកុំឱ្យមានជនរងគ្រោះពីការជួញដូរបន្ថែមទៀត។

ដើម្បីសន្និដ្ឋាននូវផ្នែកនេះ វិធីសាស្ត្រដ៏មានប្រសិទ្ធភាពមួយបន្ថែមទៀត គួរតែត្រូវបានអនុវត្តសកម្មភាពបញ្ឈប់ការរួមភេទជាមួយអនីតិជន។ <u>ប្រសិនបើ មិនមានតម្រូវការណាមួយនោះទេ ក៏មិនមានការផ្គត់ផ្គង់ដែរ។</u>

## ១. សេចក្តីផ្តើម

តំបន់ភ្លើងក្រហមដ៏ល្បីល្បាញបំផុតរបស់ប្រទេសកម្ពុជាត្រូវបានស្គាល់ថាជាតំបន់ស្វាយប៉ាកត្រូវបានបិទជាផ្លូវការនៅចុងរដូវក្តៅឆ្នាំ ២០០៤។ ការណ៍នេះ អនុវត្តន៍តាមអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិជាច្រើន ហើយនគរបាលបានធ្វើការវាយឆ្មក់ក្នុងតំបន់ស្វាយប៉ាក ដែលជាកន្លែងជនសង្ស័យត្រូវបានចាប់ខ្លួនហើយ ជនរងគ្រោះពីការជួញដូរផ្លូវភេទត្រូវបានសង្គ្រោះ។ ប្រសិនបើ យើងស្វាគមន៍យ៉ាងពេញទំហឹងនូវការបិទនូវតំបន់ស្វាយប៉ាករបាយការណ៍នេះមានគោលបំណងលើកឡើងពីផលវិបាកនៃការបិទនេះ បន្ទាប់ពីរយៈពេលបីខែដែលនគរបាលបានព្យាយាមឃ្លាំមើលសកម្មភាពនានាក្នុងតំបន់ស្វាយប៉ាក។ ដើម្បីស្វែងយល់នូវភាពស្មុគស្មាញនៃការជួញដូរ និងបញ្ហាទេសចរណ៍ផ្លូវភេទលើកុមារក្នុងតំបន់ស្វាយប៉ាក និងដើម្បីពន្យល់នូវការកើនឡើងថ្មីៗនៃអំពើពេស្យាចារ យើងនឹងលើកឡើងនូវប្រវត្តិរបស់ភូមិនេះក្នុងផ្នែកទីមួយ។ បន្ទាប់មកយើងនឹងសិក្សាស្វែងយល់ពីការឆ្លើយតបរបស់អង្គការក្រៅរដ្ឋាភិបាល អន្តរជាតិក្នុងលក្ខខណ្ឌនៃការអនុវត្តន៍គោលការណ៍បង្ក្រាប ឬអន្តរាគមន៍។ ផ្នែកទី៣ នឹងផ្តល់នូវឧទាហរណ៍ អំពីការធ្វើអន្តរាគមន៍របស់នគរបាល និងអង្គការក្រៅរដ្ឋាភិបាលព្រមទាំងមូលហេតុនៃកម្រិតដែលមានប្រសិទ្ធផលសំខាន់តិច ឬច្រើន។ យើងនឹងធ្វើការសន្និដ្ឋានត្រឹមស្ថានភាពបច្ចុប្បន្នក្នុងតំបន់ស្វាយប៉ាក។

## ២. ប្រវត្តិ

វិស័យទេសចរណ៍ កំពុងមានការកើនឡើងយ៉ាងខ្លាំងក្លាក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនាំមកនូវការផ្លាស់ប្តូរដ៏ធំធេងនៃតរិយាបថ និងអាកប្បកិរិយា។ ក្នុងចំណោមបញ្ហាទាំងនេះភ្ញៀវទេសចរផ្លូវភេទ និងភ្ញៀវទេសចរផ្លូវភេទលើកុមារបង្ហាញនូវផ្នែកមួយ ដែលកំពុងតែកើនឡើងនៃផលប្រយោជន៍របស់ភ្ញៀវទេសចរពីគោលការណ៍និងសកម្មភាពអនុវត្តច្បាប់ធូររលុង។ ប្រសិនបើរដ្ឋាភិបាលមានឆន្ទៈខ្លាំងក្លាបញ្ហាសំខាន់គឺ វាប្រឈមនឹងកម្រិតប្រាក់ខែទាប ដែលកំពុងដើរតួនាទីដ៏សំខាន់ក្នុងការមិនអនុវត្តន៍យុទ្ធសាស្ត្ររដ្ឋាភិបាល។ លើសពីនេះទៅទៀត ស្ថានភាពនោះ នៅតែមិនមានភាពច្បាស់លាស់ជាមួយនឹងការពាក់ព័ន្ធរបស់មន្ត្រីក្នុងការជួញដូរមនុស្ស។ ជាផលវិបាកអំពើពេស្យាចារ និងជាពិសេសទេសចរណ៍ផ្លូវភេទបានបើកយ៉ាងងាយស្រួលសម្រាប់ជនបរទេស និងអតិថិជនក្នុងស្រុក។ បណ្តាញការងារត្រូវបានបង្កើតឡើងក្នុងតំបន់តិចតួចដូចជាតំបន់ស្វាយប៉ាកពីមុន ដោយផ្តល់កុមារទៅឱ្យជនអនាចារបច្ចឹមប្រទេស ឬក៏ទៅឱ្យអ្នកស្វែងរកព្រហ្មចារីនៅអាស៊ីផងដែរ។ ដោយមិនអាចចៀសរួចភាពក្រីក្រនឹងធ្វើឱ្យងាយស្រួលដល់ការជួញដូរកុមារ និងក្មេងស្រីព្រហ្មចារី ដែលគ្រួសារជំពាក់បំណុលគេជាច្រើនគិតអំពីឱកាសធ្វើយ៉ាងណាដើម្បីសងបំណុលគេឱ្យបានឆាប់។ តាមពិតទៅក្មេងស្រី ដែលមានអាយុច្រើនជាងគេក្នុងគ្រួសារនឹងត្រូវបានលក់ដោយស្ម័គ្រចិត្តទៅឱ្យមេបន ឬម្ចាស់ផ្ទះបន។ ក្នុងបរិបទនៃការរំលោភបំពានលើកុមារសំណួរតិចតួចអំពីទំនាក់ទំនងរវាងការសុំទាន និងពេស្យាចារនៅតែមិនទាន់អាចឆ្លើយបាន។ តើគ្រួសារមួយអាចទទួលយក

បានដោយរបៀបណាក្នុងការលក់កូនមួយក្នុងចំណោមកូនជាច្រើនរបស់ខ្លួនសម្រាប់គោលបំណងផ្លូវភេទ? តើពួកគេដឹងអំពីផលវិបាកផ្លូវចិត្ត និងផ្លូវកាយដែរឬទេ? តើពួកគេមានមនសិការអំពីសកម្មភាពបែបនេះ ដែលផ្ទុយនឹងធម្មជាតិដែរឬទេ ?

ក្នុងបរិបទនេះចាប់តាំងពីឆ្នាំ ១៩៩៨ មកស្វាយប៉ាកបាន និងកំពុងទទួលយកជាចំហនូវក្មេងស្រី និងកុមាររកស៊ីផ្លូវភេទ។ ការកើនឡើងនៃតម្រូវការគឺ ជារឿងយ៉ាងសំខាន់ និងអាចមើលឃើញជាក់ស្តែងជាងសកម្មភាពដែលត្រូវបានចាប់ផ្តើមអនុវត្ត ដោយអង្គការក្រៅរដ្ឋាភិបាលក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គភាពនគរបាល។ ប៉ុន្តែទោះបីជាមានការសែតចុះផ្សាយ និងសម្ពាធពីអន្តរជាតិយ៉ាងណាក៏ដោយ ការបិទតំបន់ស្វាយប៉ាកបានចំណាយរយះពេលយ៉ាងយូរទម្រាំលេចចេញជារូបរាង។

## ៣. គោលដៅនៃការសិក្សា

សព្វថ្ងៃនេះ បញ្ហាសម្របសម្រួលដ៏ខ្លាំងក្លាក្លាយជាបញ្ហាបើកចំហ ដែលអាចមើលឃើញគ្រប់កម្រិតនៃដំណើការអភិវឌ្ឍន៍។ បញ្ហារទាំងនេះកើតឡើងរវាងរដ្ឋរវាងអង្គការអន្តរជាតិ និងរវាងអង្គការក្រៅរដ្ឋាភិបាលដោយលទ្ធផលលេចចេញពីការវិវាទផលប្រយោជន៍ផ្នែកវប្បធម៌ នយោបាយ ឬសេដ្ឋកិច្ច។ ជាការពិតមូលនិធិទាំងឡាយនឹងត្រូវផ្តល់ឱ្យអង្គការក្រៅរដ្ឋាភិបាល អាស្រ័យលើការគោលការណ៍ និងគោលនយោបាយរបស់ម្ចាស់ជំនួយ។ ជួនកាលជម្រើសនយោបាយ ឬសាសនា ក៏អាចដើរតួនាទីដ៏សំខាន់ផងដែរក្នុងគោលបំណងផ្សេងៗគ្នាទាំងនេះ។

ការសិក្សារនេះរំពឹងថា នឹងមានការដោះស្រាយទាន់ពេលនូវដំណើរការជារួម ដែលកំពុងមានការរិះគន់ចំពោះការទទួលខុសត្រូវរបស់រដ្ឋាភិបាល ប៉ុន្តែក៏ជាបញ្ហាដែលត្រូវបានបង្កើតដោយដំណើការនិង ទស្សនះរបស់អង្គការក្រៅរដ្ឋាភិបាលផ្សេងៗគ្នាដោយកង្វះការសម្របសម្រួល និងសេចក្តីត្រូវការនៃការយល់ដឹង ព្រមទាំងនិរន្តភាពសម្រាប់កម្មវិធីអង្គការក្រៅរដ្ឋាភិបាលនានា។

## ៤. គោលបំណងនៃការស្រាវជ្រាវ

ការងារនេះមានគោលបំណងផ្តល់នូវការតាមដានលើការធ្លាក់ចូលតំបន់ស្វាយប៉ាក និងដើម្បីវិភាគលើស្ថានភាពបច្ចុប្បន្នសម្រាប់ការផ្តល់នូវ :

⇨ ការប៉ាន់ប្រមាណលើផលប៉ះពាល់នៃការធ្លាក់ចូលផ្ទះបនស្តីពី បណ្តាញពេស្យាចារ និងការជួញដូរក្នុងតំបន់ស្វាយប៉ាក។

- ⇨ ការប៉ាន់ប្រមាណលើផលប៉ះពាល់នៃការឆ្មក់ចូលផ្ទះបនស្ដីពី ការរីករាលដាលនៃពេស្យាចារពីតំបន់ស្វាយប៉ាក និងផលវិបាកសម្រាប់ក្មេងស្រី និងអនីតិជនដែលរកស៊ីផ្លូវភេទ។
- ⇨ ការប៉ាន់ប្រមាណលើផលប៉ះពាល់នៃការឆ្មក់ចូល និងការបិទផ្ទះបនស្ដីពីជីវិតសហគមន៍ក្នុងតំបន់ស្វាយប៉ាក។
- ⇨ ការប៉ាន់ប្រមាណលើផលប៉ះពាល់នៃការឆ្មក់ចូលស្ដីពី សកម្មភាពសង្គម និងសកម្មភាពសហគមន៍ដោយអង្គការក្រៅរដ្ឋាភិបាលដទៃៗទៀត។

## ៥. ប្រវត្តិភូមិ

ទិន្នន័យក្នុងឯកសារនេះទទួលបានមកពីរឿងរ៉ាវភស្តុតាង និងសាក្សីជាច្រើន។ ការគួរឱ្យជឿទុកចិត្តបានទាំងនេះពឹងផ្អែកទៅលើបទពិសោធន៍ដ៏រឹងមាំស្តីពីអកប្បកិរិយា និងស្ថានភាពអ្នកភូមិ ប៉ុន្តែយើងឯកភាពថា អ្នកផ្តល់ព័ត៌មានជួនកាលមានការបំភ្លៃ ហើយមិនផ្តល់ព័ត៌មានទាំងអស់ទេ។

### ៥.១ ការពិពណ៌នាភូមិ និងប្រជាជន

ស្វាយប៉ាកស្ថិតនៅចម្ងាយ ១១ គីឡូម៉ែត្រពីទីក្រុងភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ ៥។ ភាគច្រើនគ្រួសារវៀតណាម (មានប្រមាណ ៩០%នៃអត្រាប្រជាពលរដ្ឋ) រស់នៅក្នុងភូមិនេះ។ ពួកគេភាគច្រើនមកពីប្រទេសវៀតណាមដោយគ្មានលិខិតឆ្លងដែន ឬលិខិតស្នាមផ្លូវការនោះទេ។ គ្រួសារទាំងនេះមកពីបណ្តាខេត្តនៃប្រទេសវៀតណាមផ្សេងៗរួមមាន Long An, Tien Giang, Dong Thap, Vinh Long, An Giang, Kien Giang, Minh Hai, Ca Tho, Sroc Trang, Ta Vinh, Ben Tre , Tay Ninh, និង ក្រុង Ho Chi Minh ។

សម្រាប់ព័ត៌មានបន្ថែមអំពីប្រវត្តិស្វាយប៉ាក ការសិក្សាមួយដោយលោកបេយ័រ[២] (Baker) នឹងផ្តល់នូវប្រវត្តិភូមិនេះយ៉ាងច្បាស់លាស់ពីឆ្នាំ ១៩៨៥ ដែលជាកន្លែងផ្តល់សេវាកម្មផ្លូវភេទដំបូងបំផុតរហូតដល់ ខែមីនា ឆ្នាំ ២០០២ :

**"ផ្ទះបនដំបូង គឺជាផ្ទះខ្ទមធ្វើឡើងពីឫស្សី និងប្រក់ស្លឹកត្នោតដែលមានស្រីរកស៊ីផ្លូវភេទពី ២ ទៅ ៥ នាក់។ ផ្ទះខ្ទមទាំងនេះធំល្មមដែលមានគ្រែ២ ដោយមានការបាំងវាំងននដាច់ដោយឡែកពីគ្នា។ ផ្ទះបនទាំងនេះមានលក្ខណៈសាមញ្ញណាស់ មិនមានអគ្គិសនី គ្រែគ្មានពូក ហើយមានបន្ទប់ទឹកតែមួយប៉ុណ្ណោះ ហើយបន្ទប់ទឹកនោះនៅខាងក្រៅផ្ទះខ្ទមនោះ។"**

---

[២] បេយ័រ ស៊ីម៉ុន , សារ៉ាន់ដា លី , សារ៉ុន អ៊ុន , ហ្សាខា ហួម អេម និង សាម៉ុន អ៊ុន *"ការលើកកម្ពស់អត្ត សញ្ញាណសហគមន៍ និងការចូលរួមក្នុងសហគមន៍"*

ដូចដែលបានជម្រាបជូននៅក្នុងរបាយការណ៍នេះ យោងទៅលើអ្នកស្រុកដែលរស់នៅក្នុងតំបន់ស្វាយប៉ាក រយៈពេលយូរបានឱ្យដឹងថា ចំនួនផ្ទះបនបានកើនឡើងយ៉ាងខ្លាំងនៅពេលអ៊ុនតាក់មកដល់ក្នុងឆ្នាំ ១៩៩២ ពី ៣០ ទៅ ៥០ ខ្នង ហើយនៅតំបន់នោះមានចំនួនស្រីរកស៊ីផ្លូវភេទកើនឡើងប្រហែលពី ៣៦០នាក់ ទៅ ៥០០នាក់។ អ្នកនិពន្ធចង្អុលបង្ហាញនូវរបាយការណ៍មួយពី Cuc និង Flamm (១៩៩៦ : ១១២) ដែលមានបំណងបង្ហាញពីអត្រាប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់ ដែលរកស៊ីផ្លូវភេទនៅពេលនោះចន្លោះពី ៧០០ ទៅ ៩០០នាក់។ នៅឆ្នាំ ១៩៩៥ អង្គការគ្រូពេទ្យគ្មានព្រំដែន (MSF) បានបង្កើតគ្លីនិកជម្ងឺកាមរោគនៅក្នុងតំបន់ស្វាយប៉ាក រហូតដល់ចុងក្រោយផ្តល់នូវសេវាកម្មសង្គមនៅក្លឹបផ្កាឈូកចំពោះសហគមន៍រកស៊ីផ្លូវភេទ។

ព្រឹត្តិការណ៍ខាងក្រៅក៏ដើរតួនាទីសំខាន់ផងដែរក្នុងតំបន់ស្វាយប៉ាកដោយមានអគ្គីភ័យ ២ដង ក្នុងឆ្នាំ ២០០២ និងឆ្នាំ ២០០៥ ដែលបានបំផ្លិចបំផ្លាញនូវផ្ទះបនទាំងស្រុង។ ទាំងពីលើកនេះផ្ទះបនត្រូវបានសាងសង់ឡើងវិញដោយមានផ្ទះបនកាន់តែច្រើន ដោយមានការរីកចម្រើនផ្នែកសេវាកម្មមូលដ្ឋាន និងផ្នែកសេវាកម្មផ្នែកសុខភាព ដូចជាមានអគ្គិសនី ទឹក ....។

## ៥.២ សកម្មភាពសេដ្ឋកិច្ច និងសង្គម

ជាដំបូង ប្រសិនបើតំបន់ស្វាយប៉ាកមានការល្បីល្បាញជាលក្ខណៈអន្តរជាតិថា ជាតំបន់រកស៊ីផ្លូវភេទដែលត្រូវបានផ្សព្វផ្សាយតាមរយៈវេបសាយ[៣] និងពាក្យសំដីនិយាយតៗគ្នា ជាពិសេសស្វាយប៉ាកគឺជាភូមិមួយ ដែលមានជីវិត សេដ្ឋកិច្ច និងសង្គម។ រយៈពេលជាច្រើនឆ្នាំមកទៀត សកម្មភាពសេដ្ឋកិច្ចសង្គមត្រូវបានអភិវឌ្ឍន៍ដោយទទួលបានផលប្រយោជន៍ប្រយោល និងផ្ទាល់ពីអំពើពេស្យាចារ។

ជាការពិត ការអភិវឌ្ឍន៍នៃសកម្មភាពសេដ្ឋកិច្ចណាមួយនឹងបង្កើតបាននូវបណ្តាញមួយនៃសកម្មភាពសេដ្ឋកិច្ច ឬជំនួញដែលមានទំនាក់ទំនងគ្នាដោយផ្ទាល់ ឬប្រយោលដទៃទៀត។ ដូច្នេះបារ ភោជនីយដ្ឋាន ហាងអ៊ុតសក់ និងផ្សេងៗបានបង្កើតឱ្យមានបណ្តាញសេដ្ឋកិច្ច ដែលបានពាក់ព័ន្ធនឹងជំនួញផ្លូវភេទ។ ដំបន់ភ្លើងក្រហមឆ្លើយតបដំបូងគេបង្អស់ជាតំបន់រស់នៅ។ សកម្មភាពសេដ្ឋកិច្ចស្របច្បាប់ជាច្រើន គឺជាផ្នែកមួយនៃបណ្តាញសេដ្ឋកិច្ចសកល ដែលរាប់បញ្ចូល ហើយភាគច្រើនឈានទៅរកសកម្មភាពខុសច្បាប់។

ក្នុងតំបន់ស្វាយប៉ាកសកម្មភាពទាំងអស់នេះរួមមានល្បែងស៊ីសង និងការជល់មាន់ខុសច្បាប់បានកើតឡើង ហើយសព្វថ្ងៃនេះកំពុងវិនាសពីការបិទនេះ។ ការស្ទង់មតិខ្លីមួយក្នុងចំណោមប្រជាជនត្រូវបានធ្វើឡើង ដើម្បីប៉ាន់

---

[៣] សកម្មភាពក្នុងចំណោមប្រជាពលរដ្ឋនៃអ្នករកស៊ីផ្លូវភេទ ដែលជំពាក់បំណុលគេក្នុងតំបន់ស្វាយប៉ាក, ក្រុមប្រឹក្សាអគ្គាប្រជាពលរដ្ឋ ទំព័រទី ៤៤ កម្ពុជា ឆ្នាំ ២០០៣
http://www.zenbuckaroo.com/zentours_cambodia_2000.htm
http://www.erotictravel.com_newsltr.htm

ប្រមាណលើផលប៉ះពាល់នៃការធ្លាក់ចូល និងការបិទផ្ទះបនស្តីពីជីវិតអ្នកសហគមន៍នៅតំបន់ស្វាយប៉ាក។ លទ្ធផលនឹងត្រូវបានពិពណ៌នានៅពេលក្រោយក្នុងឯកសារនេះ។

សកម្មភាពមួយចំនួនតូចទៀតដូចជាសេវាថ្នាំពេទ្យ គ្លីនិកឯកជន ក៏មាននៅក្នុងតំបន់ស្វាយប៉ាកនោះផងដែរ។ ជាក់ស្តែង ក្មេងស្រីរកស៊ីផ្លូវភេទមួយចំនួនមិនចង់ទៅកាន់គ្លីនិកអង្គការក្រៅរដ្ឋាភិបាលទេដោយភ័យខ្លាចថាបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលស្តីបន្ទោសពួកគេ ដែលមិនបានប្រើប្រាស់ស្រោមអនាម័យជាមួយភ្ញៀវ។ ដូច្នេះពួកគេចូលចិត្តទៅកាន់កន្លែងលក់ថ្នាំដើម្បីព្យាបាលដោយខ្លួនឯង ប៉ុន្តែថ្នាំទាំងនោះមិនអាចព្យាបាលបាន ហើយពួកគេនៅតែមានបញ្ហា។ លើសពីនេះទៀត ក្មេងស្រីរកស៊ីផ្លូវភេទជាច្រើនទៅកាន់គ្លីនិកឯកជនដើម្បីពន្លូតកូន គ្លីនិកនេះនៅមិនឆ្ងាយពីផ្ទះបនទាំងនោះទេ ហើយពេទ្យឆ្មបអនុញ្ញាតិឱ្យអ្នករកស៊ីផ្លូវភេទបង់លុយជាក្រោយ (ករណីណាមួយដែលពួកគេមិនទាន់មានលុយ ហើយពួកគេអាចបង់លុយពេលក្រោយ)។ ក្មេងស្រីរកស៊ីផ្លូវភេទខ្លះបានអះអាងថា ពេទ្យឆ្មបនោះមិនមានចំណេះវិជ្ជាគ្រប់គ្រាន់ទេ។

### ៥.៣ ពេស្យាចារ និងការវិវត្តន៍ (ចំនួនលក្ខណៈចម្មជាតិ និងអាកប្បកិរិយា)

លើកលែងឆ្នាំ ១៩៩២-១៩៩៣ ត្រូវបានគេចាត់ទុកជាតំណាក់កាលមាសប្រាក់នៃតំបន់ស្វាយប៉ាក ដោយមានវត្តមានអ៊ុនតាក់ ជាពិសេសជនបរទេស ចាប់ផ្តើមមកតំបន់ស្វាយប៉ាកពីឆ្នាំ ១៩៩៨ រហូតមក។ ពីមុនភ្ញៀវដ៏ច្រើនលើសលប់គឺខ្មែរ និងវៀតណាម។ ការស្ទង់មតិធ្វើឡើងដោយអង្គការ AIDéTouS[៤] ក្នុងខែធ្នូ ឆ្នាំ ២០០១ បន្ទាប់មកឆ្នាំ ២០០២ ផ្តល់នូវការប៉ាន់ប្រមាណដំបូងនៃការមកជាញឹកញាប់របស់ភ្ញៀវ ប៉ុន្តែថែមទាំងលើប្រភេទ និងឥរិយាបថនៃសេចក្តីត្រូវការផងដែរ។ នៅទីនេះ យើងក៏អាចជជែកអំពីតួរលេខនៃការផ្គត់ផ្គង់ ប៉ុន្តែយើងចាត់ទុកសេចក្តីត្រូវការនោះជាក្បាលម៉ាស៊ីននៃអំពើពេស្យាចារគ្រប់ប្រភេទទាំងអស់។ តារាងខាងក្រោម ផ្តល់នូវការសង្ខេបជាសរុបនៃការមកជាញឹកញាប់របស់ភ្ញៀវក្នុងតំបន់ស្វាយប៉ាក និងការវិវត្តន៍របស់វា។

| សញ្ជាតិ | ខ្មែរ | ចិន | វៀតណាម | ជប៉ុន | ពួកបច្ចឹមប្រទេស | ផ្សេងៗ | សរុប |
|---|---|---|---|---|---|---|---|
| ខែធ្នូ ឆ្នាំ ២០០១ | ៩០៧ | ២២៤ | ៣៥៥ | ៥៣៧ | ៦៧៦ | ១៤៤ | ២៨៣៣ |
| ខែធ្នូ ឆ្នាំ ២០០២ | ១៤៦៣ | ៥០៥ | ៧៤៩ | ៥២៦ | ៩៥៨ | ១៣ | ៤២១៤ |
| អត្រាកើនឡើង | +៦១ % | | | | + ៤២ % | | + ៤៩% |

[៤] សមាគមអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍ ទេសចរណ៍ និងសុខភាព

## តារាងលេខ ១ : ចំនួនភ្ញៀវដែលមកស្វាយប៉ាក បែងចែកជាសញ្ជាតិ

ទិន្នន័យទាំងនេះស្តីពី ការមកជាញឹកញាប់របស់ភ្ញៀវនៅតំបន់ស្វាយប៉ាក បង្ហាញនូវចំនួនសរុបមាន ៤២១៤នាក់ ដែលត្រូវបានចុះបញ្ជីថាជាអ្នកមកក្នុងគោលបំណងរួមភេទក្នុងខែធ្នូ ឆ្នាំ ២០០២ មានន័យថា មានការកើនឡើង ២៩.២៧% ប្រៀបធៀបទៅនឹងរដូវក្តៅឆ្នាំ ២០០២ ហើយ ៤៩% ច្រើនជាងកាលពីខែធ្នូ ឆ្នាំ ២០០១។ ពេលនេះដែរ ការមកញឹកញាប់របស់ពួកបច្ចឹមប្រទេសគឺ ៤២% ច្រើនជាងខែធ្នូ ឆ្នាំ ២០០១ ហើយមាន ២៣% នៃចំនួនសរុប។ ដើម្បីដឹងច្បាស់អំពីប្រភេទនៃតម្រូវការរបស់អតិថិជន ក្រុមគោលដៅត្រូវបានសួរសំណួរជាច្រើនស្តីអំពីឥរិយាបថរបស់ភ្ញៀវ (អាយុជនអនាចារ អ្នកប្រើប្រាស់ គ្រឿងញៀន អំពើហិង្សា ការប្រើប្រាស់ស្រោមអនាម័យ...)។ ជាឧទាហរណ៍ ជនជាតិជប៉ុន និងពួកបច្ចឹមប្រទេសមានការប្រើប្រាស់ស្រោមអនាម័យក្នុងកម្រិតទាប គឺក្នុងចំណោមជនជាតិជប៉ុនមាន ៦៥% និងពួកបញ្ចឹមប្រទេសមាន ៤១% ប៉ុណ្ណោះ ដែលអះអាងនូវនិន្នាការរបស់គេចំពោះអនាចារលើកុមារនៅខណៈពេល ដែលការស្ទង់ស្ទាបដទៃទៀតបង្ហាញថា ពួកគេប្រើស្រោមអនាម័យអំឡុងពេលរួមភេទជាមួយស្រីមិនបរិសុទ្ធ។ ប៉ុន្តែមិនប្រើស្រោមអនាម័យដែលឆ្លើយតបទៅនឹងតំរូវការខ្ពស់នៃការរួមភេទតាមមាត់ (ប្រហែល ៥០% នៃភ្ញៀវជនជាតិជប៉ុន និងបច្ចឹមប្រទេសរាប់បញ្ចូលទាំងជនអនាចារលើកុមារ) ទោះបីជាក្មេងស្រី ឬក្មេងប្រុសនោះមានអាយុប៉ុន្មានក៏ដោយ។ រឿងដែលគួរឱ្យភ្ញាក់ផ្អើលនោះគឺថា ស្វាយប៉ាកមិនមានការចែកចាយនូវអតិថិជនដដែល១ដូចក្នុងក្រុងភ្នំពេញ ដែលអតិថិជនចិនមានច្រើន ហើយពាក់ព័ន្ធក្នុងការជួញដូរមនុស្សជាមួយ និងតំរូវការខ្លាំងពិសេសគឺ អ្នកស្វែងរកព្រហ្មចារី។

ចំណុចដែលគួរឱ្យចាប់អារម្មណ៍មួយទៀត គឺទំនាក់ទំនងផ្ទុយគ្នារវាងការកើនឡើងនៃចំនួនភ្ញៀវ និងការធ្លាក់ចុះនៃអត្រាប្រជាជនដែលរកស៊ីផ្លូវភេទអំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ភាគច្រើនបណ្តាលមកពីភ្លើងឆេះ ២លើក ក្នុងឆ្នាំ ១៩៩២ និងឆ្នាំ ១៩៩៥ ចំនួនស្ត្រីរកស៊ីផ្លូវភេទធ្លាក់ចុះជាង ៥០%។ ការធ្លាក់ចុះនេះមានន័យថា ការកើនឡើងចំនួនភ្ញៀវលើស្ត្រីរកស៊ីផ្លូវភេទ និងផលិតភាពរបស់ពួកគេ។ ព័ត៌មាននេះបានគូសបញ្ជាក់នូវតម្រូវការកើនឡើងដ៏ខ្លាំងចំពោះការរួមភេទជាមួយអនីតិជនក្នុងតំបន់ស្វាយប៉ាក។ ដូច្នេះការស្តាប់ស្ទង់របស់អង្គការ AIDéTouS មួយបន្ថែមទៀតបានរៀបចំក្នុងចំណោមយុវវ័យ ២៥នាក់ មានក្មេងស្រី និងក្មេងប្រុសដែលត្រូវបានគេបង្ខំឱ្យធ្វើជាពេស្យានាំមកនូវលទ្ធផលដូចខាងក្រោម :

**តារាងលេខ ២ : ចរិតលក្ខណៈរបស់កុមារ និងសកម្មភាព រួមភេទរបស់គេជាមួយភ្ញៀវ**

| ភេទ | ចំនួនសរុប | អាយុមធ្យមគិតត្រឹមពេលស្លង់មតិ | អាយុមធ្យមគិតត្រឹមពេលប្រព្រឹត្តិលើកដំបូង (តាមមាត់ រន្ធយោនី ឬរន្ធគូទ) | សញ្ជាតិភ្ញៀវដំបូង | ចំនួនភ្ញៀវក្នុងមួយថ្ងៃ | ប្រាក់ចំណូលក្នុងទំនាក់ទំនងនីមួយៗជាមួយភ្ញៀវ |
|---|---|---|---|---|---|---|
| ក្មេងស្រី | ១៨ | ១៤.២ | ១២.៩ | ពួកបញ្ចឹម ៨<br>ជប៉ុន ៦<br>ចិន ៣<br>ខ្មែរ ១ | ១-៣ | ២-៥ ដុល្លា |
| ក្មេងប្រុស | ៧ | ១៣.៣ | ១២.៣ | ពួកបញ្ចឹម ៥<br>ជប៉ុន ២ | ១-២ | ៥-១០ ដុល្លា |

ការពាក់ព័ន្ធទៅនឹងការណែនាំអោយចូលអំពើពេស្យាចារ :

- ចាប់តាំងពីពេលនោះមកអន្តរាគមន៍របស់សម្រាប់ក្មេងប្រុស : ពួកគេទទួលបានរវាង ៥០ និង ១០០ ដុល្លា ចំពោះការរួមភេទដំបូងបន្ទាប់មក ២០ ដុល្លា ចំពោះការរួមភេទតាមគូទ និង ៥ ដុល្លា សំរាប់ការរួមភេទ តាមមាត់ ...។
- សម្រាប់ក្មេងស្រី : ពួកគេទទួលបាន ៣០០ ដុល្លា ទៅ ៥០០ដុល្លា ចំពោះការលក់ព្រហ្មចារីរបស់ពួកគេ។ ក្មេងស្រីព្រហ្មចារីយ៍អាចត្រូវបានលក់ជាច្រើនដងក្នុងរយៈពេល ២សប្តាហ៍ដំបូង ក្រោយពីនាងបានអស់ព្រហ្មចារីយ៍ក្នុងតម្លៃមួយដងមួយរយដុល្លា។ បន្ទាប់ពីរយៈពេលបីសប្តាហ៍តម្លៃធ្លាក់ចុះរវាង ៧០ដុល្លា និង ៨០ ដុល្លា ចុងក្រោយឈានរហូតដល់ ៥ដុល្លា បន្ទាប់ពីរយៈពេល ១ខែ ឬ ២ខែ។

អង្គការក្រៅរដ្ឋាភិបាល និងនគរបាលបានជួយដើម្បីបញ្ឈប់ការផ្គត់ផ្គង់ពាណិជ្ជកម្មផ្លូវភេទទៅឱ្យពួកបច្ចឹមប្រទេសដោយកុមារ ឬក្មេងស្រីរកស៊ីផ្លូវភេទក្នុងភូមិនេះ។

## ៦. ប្រវត្តិអង្គការក្រៅរដ្ឋាភិបាលក្នុងតំបន់ស្វាយប៉ាក

ចាប់តាំងពីឆ្នាំ ១៩៩៥ អង្គការក្រៅរដ្ឋាភិបាលបានបង្កើតការិយាល័យមួយក្នុងតំបន់ស្វាយប៉ាកក្នុងការឆ្លើយតបទៅនឹងការទទួលស្គាល់តម្រូវការ ដើម្បីផ្តល់នូវសេវាមនុស្សធម៌ និងការប្រមូលព័ត៌មាន។ ព័ត៌មានបែប

នេះជួយក្នុងការប្រមូលឯកសារនៃការវិវត្តន៍របស់សហគមន៍ ហើយវាមានប្រយោជន៍សម្រាប់ធ្វើសេចក្តីព្រាងគោលនយោបាយ ដែលពាក់ព័ន្ធគ្រប់ទិដ្ឋភាពសកម្មភាពនៃការធ្វើពាណិជ្ជកម្មផ្លូវភេទទាំងអស់ក្នុងមូលដ្ឋាន។ ក្រោយៗមកទៀតមាន : ការកេងប្រវ័ញ្ចលើប្រជាជនដែលរកស៊ីផ្លូវភេទ (ជាពិសេសកុមារ) ដោយអតិថិជនអន្តរជាតិ និងក្នុងស្រុកការបែងចែកសហគមន៍តាមប្រពៃណី និងតម្លៃគ្រួសារ ការរីករាលដាលនៃជម្ងឺកាមរោគ ឬការឆ្លងមេរោគទេសចរណ៍ផ្លូវភេទ និងការផ្តល់នូវការងារដែលអាចជ្រើសរើសបានសម្រាប់ប្រជាជនដែលរកស៊ីផ្លូវភេទ។ ការផ្តល់សេវា (ចំពោះសហគមន៍ដែលទទួលរងការកេងប្រវ័ញ្ច) ដោយអង្គការក្រៅរដ្ឋាភិបាល ជាធម្មតាមានការកម្រិតម៉ោងធ្វើការប្រចាំសប្តាហ៍។ ជនដែលប្រឈមមុខ (នឹងការកេងប្រវ័ញ្ចផ្លូវភេទ) ត្រូវបានអនុញ្ញាតឱ្យធ្វើការនៅពេលយប់ និងចុងសប្តាហ៍ ឬថ្ងៃឈប់សម្រាក។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួនទៀត មានម៉ោងធ្វើការបន្ថែម ប៉ុន្តែដំណើរការនៃការទប់ស្កាត់ជាច្រើនកំពុងត្រូវបានព្យាយាមដើម្បីសង្គ្រោះជនរងគ្រោះ ព្រមទាំងចាប់ខ្លួនមេបន និងម្ចាស់ផ្ទះបន។

កាលប្រវត្តិនៃអង្គការនានាដែលមានវត្តមាននៅតំបន់ស្វាយប៉ាកមានដូចខាងក្រោម :

### ៦.១ ការផ្គត់ផ្គង់នៃការការពារ

☐ <u>**គ្រូពេទ្យគ្មានព្រំដែន**</u>

ក្នុងឆ្នាំ ១៩៩៥ ក្រុមអង្គការគ្រូពេទ្យគ្មានព្រំដែនក្នុងប្រទេសកម្ពុជា បានសម្រេចចិត្តបើកគ្លីនិកមួយនៅកន្លែងដែលស្ត្រី និងក្មេងស្រីរកស៊ីផ្លូវភេទអាចទទួលការព្យាបាលជម្ងឺ និងពិគ្រោះយោបល់ពាក់ព័ន្ធនឹងរបៀបការពារខ្លួនពីជម្ងឺ ដែលឆ្លងតាមការរួមភេទដូចជា ជម្ងឺហ៊ីវជាដើម។ តាមរយៈកម្មវិធីក្នុងតំបន់ស្វាយប៉ាក អង្គការគ្រូពេទ្យគ្មានព្រំដែនបានធ្វើការយ៉ាងជិតស្និតជាមួយអង្គការតស៊ូមតិ ដោយការផ្តល់ព័ត៌មានដល់ពួកគេអំពីឱកាសសម្រាប់ប្រតិបត្តិការសង្គ្រោះ។ តាមរយៈការពន្យល់បង្ហាញឡើងវិញនូវសកម្មភាពរបស់ពួកគេចំពោះការយកចិត្តទុកដាក់ពីជម្ងឺអេដស៍ អង្គការគ្រូពេទ្យគ្មានព្រំដែន បានសម្រេចចិត្តប្រគល់គម្រោងក្នុងតំបន់ស្វាយប៉ាកនេះទៅឱ្យអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកចំនួនពីរ[៥] គឺ គ្លីនិកស្ត្រីកម្ពុជា (CWC) ទទួលបន្ទុកផ្នែកគ្លីនិក និងអង្គការខេមរា ទទួលបន្ទុកផ្នែកសង្គម។ បច្ចុប្បន្ននេះអង្គការខេមរានៅតែបន្តរគម្រោងនេះក្នុងតំបន់ស្វាយប៉ាក ផ្ទុយទៅវិញគ្លីនិកស្ត្រីកម្ពុជាបានប្រគល់គ្លីនិកទៅឱ្យអង្គការ MEC ដែលជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយផ្សេងទៀត។

[៥] អាគាររបស់អង្គការគ្រូពេទ្យគ្មានព្រំដែន ត្រូវបានចែកជាពីរផ្នែក : ជាន់ផ្ទាល់ដីត្រូវបានប្រគល់ជូនទៅឱ្យគ្លីនិកស្ត្រីកម្ពុជាសម្រាប់បម្រើសេវាថែទាំសុខភាពបឋម និងជម្ងឺកាមរោគ ហើយជាន់ទីមួយជូនទៅអង្គការខេមរា សម្រាប់គាំពារផ្នែកសង្គម។

### ☐ **គ្លីនិកស្ត្រីកម្ពុជា** (CWC)

គ្លីនិកស្ត្រីកម្ពុជាត្រូវបានបង្កើតឡើងជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកក្នុងខែកញ្ញា ឆ្នាំ ១៩៩៨ ដោយមានការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និងគ្រប់គ្រងពីអង្គការម៉ារីស្តូបអន្តរជាតិអូស្ត្រាលី (MSIA)។ គ្លីនិកស្ត្រីកម្ពុជា ធ្វើការដើម្បីផ្តល់នូវវិធីសុវត្ថិភាពថ្មីៗ ចំពោះសុខភាពបន្តពូជ ការរៀបចំផែនការគ្រួសារ ព្រមទាំងសេវាថែទាំសុខភាពកូន និងម្តាយ។ ក្នុងឆ្នាំ ២០០១ គ្លីនិក ស្ត្រីកម្ពុជាបានគ្រប់គ្រងគ្លីនិករបស់អង្គការគ្រូពេទ្យគ្មានព្រំដែន ប៉ុន្តែបានផ្លាស់ប្តូរ គោលនយោបាយ។ ពួកគេសម្រេចចិត្តយកថ្លៃឈ្នួល ៣000រៀល សម្រាប់ការពិគ្រោះយោបល់ធម្មតាចំពោះក្មេងស្រីរកស៊ីផ្លូវភេទ ក្នុងគោលបំណងដើម្បីផ្តល់ឱ្យពួកគេនូវការចេះទទួលខុស។ ជាផលវិបាក ចំនួននៃការពិគ្រោះយោបលបានធ្លាក់ចុះយ៉ាងលឿន។ គ្លីនិកស្ត្រីកម្ពុជាបានបញ្ឈប់សកម្មភាពក្នុងតំបន់ស្វាយប៉ាក នាឆ្នាំ ២០០៣។

### ☐ **អង្គការខេមរា**

ខេមរា គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដំបូងបំផុត ដែលត្រូវបានបង្កើតក្នុងឆ្នាំ ១៩៩១ នៅពេលដែលប្រទេសកម្ពុជាបានរួចផុតពីសង្គ្រាម និងភាពឯកោរយៈពេលពីរទសវត្ស។ វាបានដើរតួនាទីមុនគេបង្អស់ក្នុងការងារលើកកម្ពស់ស្ត្រី និងកុមារ (ដែលទទួលរងនូវការបែងចែកមិនស្មើភាពក្នុងការប៉ះទង្គិចគ្នា និងជម្លោះ) ព្រមទាំងការចែករំលែកសម្រាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ការធ្វើការនៅចំកណ្តាលទីប្រជុំជននៃខ័ណ្ឌឫស្សីកែវជាយក្រុងភ្នំពេញ ភាពខ្លាំងរបស់អង្គការខេមរាថា ជាអង្គការមួយបានមកពីកម្មវិធីកម្រិតសហគមន៍របស់ខ្លួនដែលដោះស្រាយតម្រូវការរបស់អ្នកភូមិក្រីក្រ ជាពិសេសស្ត្រីនិងកុមារ។ ជាក់លាក់ជាងនេះទៅទៀត គឺដើម្បីជួយស្ត្រីឱ្យចេះពង្រឹងអំណាចដោយខ្លួនឯង តាមរយៈការជួយជ្រោមជ្រែងជាជំនាញវិជ្ជាជីវៈ ការបណ្តុះបណ្តាលអក្ខរកម្ម ការគាំទ្រផ្នែកចិត្តសាស្ត្រ និងច្បាប់សម្រាប់ស្ត្រីរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ និងការកេងប្រវ័ញ្ចផ្លូវភេទ (ក្មេងស្រីរកស៊ីផ្លូវភេទ)។ អង្គការនេះធ្វើការដើម្បីលើកស្ទួយសិទ្ធិទទួលបានការអប់រំជាមូលដ្ឋានសិទ្ធិទទួលបានការថែទាំសុខភាព ជីវភាព និងការការពារពីអំពើហិង្សាក្នុងគ្រួសារ ការពារជម្ងឺហ៊ីវ/អេដស៍ និងជម្ងឺឆ្លង តាមការរួមភេទ សុខភាពបន្តពូជ និងការរួមភេទ ព្រមទាំងយេនឌ័រ ដែលអង្គការខេមរាផ្តោតលើភាពដឹកនាំរបស់ស្ត្រីសម្រាប់ការពង្រឹងអំណាចរបស់ស្ត្រី។ ក្នុងឆ្នាំ ២០០០ អង្គការខេមរា (ជាមួយអង្គការគ្រូពេទ្យគ្មានព្រំដែន) បានសម្ភោធ **ក្លឹបផ្កាឈូក** នៅចំកណ្តាលជាន់ទីមួយនៃគ្លីនិកនេះ ដោយផ្តោតលើសុខភាពស្ត្រី និងកុមាររកស៊ីផ្លូវភេទ និងបង្ហាញពីសកម្មភាពដែលមិនប្រើប្រាស់ឱសថ។ ក្នុងឆ្នាំ ២០០២ អង្គការខេមរាបានបញ្ឈប់ការផ្តល់ការគាំពារកុមារ។

**វិធីសាស្រ្ត :** តាមរយៈទំនាក់ទំនងដោយផ្ទាល់និងប្រចាំថ្ងៃជាមួយក្មេងស្រីរកស៊ីផ្លូវភេទ អង្គការខេមរាបានលើកកម្ពស់ការអនុវត្តន៍ការរួមភេទដោយមានសុវត្ថិភាព និងលើកទឹកចិត្តអ្នកសហគមន៍ក្នុងចំណោមអ្នករកស៊ីផ្លូវភេទឱ្យជួយផ្សព្វផ្សាយព័ត៌មាននេះ។ គោលដៅនៃសកម្មភាពនេះគឺ ដើម្បីជួយស្ត្រីរកស៊ីផ្លូវភេទឱ្យមានការទទួលខុសត្រូវចំពោះសុខភាពផ្ទាល់ខ្លួនពួកគេ។ អង្គការខេមរាក៏បានគ្រប់គ្រងនូវកម្មវិធីដែលផ្តល់ដល់អ្នករកស៊ីផ្លូវភេទទាំងនេះនូវជំនាញវិជ្ជាជីវៈ និងការលើកទឹកចិត្តឱ្យសិក្សានិងរៀនសូត្រអាជីពដទៃៗទៀតក្នុងសហគមន៍ពួកគេផងដែរ។

☐ **<u>អង្គការវេជ្ជសាស្រ្តក្នុងក្តីសង្ឃឹមកម្ពុជា (MEC)</u>**

អង្គការវេជ្ជសាស្រ្តក្នុងក្តីសង្ឃឹមកម្ពុជា (MEC) ត្រូវបានបង្កើតឡើងនៅ ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ១៩៩៦ ក្រោយពីបានប្តូរមកពីអង្គការវេជ្ជសាស្រ្តក្នុងក្តីសង្ឃឹមអន្តរជាតិ (MEI)។ អង្គការវេជ្ជសាស្រ្តក្នុងក្តីសង្ឃឹមកម្ពុជា ជាអង្គការកម្ពុជាក្នុងស្រុក ដែលមិនរកប្រាក់កម្រៃ និងមិនពាក់ព័ន្ធនឹងនយោបាយ។ អង្គការនេះមានគោលបំណងបង្កើតនូវផ្នែកសុខភាព និងសុខមាលភាពរបស់អ្នកសហគមន៍ ដែលងាយរងគ្រោះបំផុតឱ្យប្រសើរជាងមុនដែលធ្វើឱ្យពួកគេអាចរីករាយ និងមានកម្រិតជីវភាពប្រសើរឡើង។

បេសកកម្មរបស់អង្គការវេជ្ជសាស្រ្តក្នុងក្តីសង្ឃឹមកម្ពុជា ផ្តោតការយកចិត្តទុកដាក់ និងសង្កត់ធ្ងន់លើការធ្វើឱ្យប្រសើរឡើងនូវសុខភាពផ្លូវកាយ និងផ្លូវចិត្តសម្រាប់ប្រជាពលរដ្ឋដែលក្រីក្របំផុត និងរងគ្រោះបំផុតដូចជាគ្រួសារទន់ខ្សោយ ជាពិសេសស្ត្រីក្មេងជំទង់ និងកុមារដែលក្រីក្របំផុតមកពីតំបន់ជនបទនៃប្រទេសនេះ។ ចាប់តាំងពីឆ្នាំ ១៩៩៨ មកអង្គការវេជ្ជសាស្រ្តក្នុងក្តីសង្ឃឹមកម្ពុជា បានបង្វែរទៅរកសេវាអភិវឌ្ឍន៍សង្គមសម្រាប់ស្ត្រី កុមារទន់ខ្សោយដែលជាជនអនាថា អ្នករកស៊ីផ្លូវភេទ ជនដែលទទួលរងនូវការរំលោភផ្លូវភេទក្មេងស្រី ដែលត្រូវបានគេកេងប្រវ័ញ្ច និងស្ត្រីទុរគត តាមរយៈកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សុខភាពមូលដ្ឋាន ការកសាងសមត្ថភាពសម្រាប់បុគ្គលិកសុខាភិបាល តាមមូលដ្ឋានដែលមានស្រាប់ និងកម្មវិធីការពារជម្ងឺហ៊ីវ/អេដស៍ ដើម្បីបន្តជីវិតពួកគេ។

ដោយមានការគាំទ្រពីអង្គការឱសថការីគ្មានព្រំដែន (PSF) ចាប់តាំងពីខែមិថុនាឆ្នាំ ២០០៣មក អង្គការវេជ្ជសាស្រ្តក្នុងក្តីសង្ឃឹមកម្ពុជាបាននឹងកំពុង បានដំណើរការគ្លីនិកជម្ងឺកាមរោគមួយក្នុងតំបន់ស្វាយប៉ាក។ បច្ចុប្បន្នមានបុគ្គលិក ចំនួន ២១នាក់ កំពុងធ្វើការនៅតាមមណ្ឌលសុខភាពក្នុងសង្កាត់ផ្សារថ្មី ១៤នាក់ ក្នុងតំបន់ស្វាយប៉ាក ហើយ ៣នាក់ ទៀតក្នុងស្រុកខ្សាច់កណ្តាល។

☐ **<u>អង្គការទស្សនៈពិភពលោក</u>**

ក្នុងតំបន់ស្វាយប៉ាក អង្គការទស្សនៈពិភពលោកបាននិងកំពុងដំណើរការក្លឹបកុមារមួយកន្លែង ដែលផ្តោតទៅលើការការពារកុមារ។ មានកុមារជាង ២០០នាក់ បានចូលរួមក្នុងសកម្មភាពក្លឹបនេះរួមមានការអប់រំអំពីសិទ្ធិ

កុមារ ការអប់រំក្រៅប្រព័ន្ធបណ្ណាល័យ ការយល់ដឹងអំពីជំងឺហ៊ីវ/អេដស៍ និងជំនាញខាងតន្ត្រី/ការកំសាន្ត។ គំរោងនេះបានផ្តល់ឥណទានខ្នាតតូចសម្រាប់គ្រួសារក្រីក្រក្នុងតំបន់ស្វាយប៉ាកដើម្បីចាប់ផ្តើមប្រកបមុខរបរ ដូច្នេះពួកគេអាចផ្គត់ផ្គង់ខ្លួនឯង និងគ្រួសារបាន។ គោលបំណងនៃគម្រោងនេះគឺ ដើម្បីការពារការជួញដូរកុមារ និងការរំលោភផ្លូវភេទលើកុមារ។ អង្គការទស្សនៈពិភពលោកផ្តោតជាសំខាន់លើអាយុជីវិតកុមារ និងគ្រួសារដែលក្រីក្របំផុត ដោយមិនគិតពីជំនឿ សាសនា ភេទ ឬសាវតាជនជាតិ ហើយមិនគិតពីប្រាក់កម្រៃ។

គម្រោងបច្ចុប្បន្នរបស់អង្គការទស្សនៈពិភពលោក ដែលមានមូលដ្ឋានក្នុងតំបន់ស្វាយប៉ាកមានការប្តេជ្ញាចិត្តរយៈពេលវែងដើម្បីធ្វើការជាមួយប្រជាពលរដ្ឋតាមសហគមន៍ក្នុងការដោះស្រាយបញ្ហាភាពក្រីក្រ និងទទួលជោគជ័យខាងការអភិវឌ្ឍន៍ដែលកាន់តែប្រសើរឡើង។

## ៦.២ សកម្មភាពទប់ស្កាត់ និងសង្គ្រោះ

☐ **<u>អង្គការ AFESIP</u>**

បេសកកម្មរបស់អង្គការ AFESIP គឺទប់ស្កាត់នូវបញ្ហា និងផលវិបាកនៃការជួញដូរស្ត្រី និងកុមារពីការធ្វើជាទាសករផ្លូវភេទដើម្បីព្យាបាល និងស្តារនីតិសម្បទារជន ដែលត្រូវបានគេសង្គ្រោះចេញពីទាសករផ្លូវភេទដើម្បីផ្តល់នូវជំនាញអាជីព និងធ្វើសមាហរណកម្មចំពោះជនដែលត្រូវបានសង្គ្រោះទាំងនោះទៅក្នុងសហគមន៍វិញប្រកបដោយនិរន្តភាព និងលក្ខណៈថ្លៃថ្នូរ។ តាមមធ្យោបាយនេះជួនកាលអង្គការ AFESIP បានជួយសង្គ្រោះស្ត្រី និងកុមារដែលត្រូវបានជួញដូរពីតំបន់ស្វាយប៉ាក។ អន្តរាគមន៍ទាំងនេះពឹងផ្អែកលើការស៊ើបអង្កេតដែលបានផ្តល់នូវភស្តុតាងថា មនុស្សទាំងអស់នោះត្រូវបានបង្ខំឱ្យរកស៊ីផ្លូវភេទ។ វិធានការរបស់អង្គការ AFESIP មានកម្រិតទាក់ទងដ៏តូចមួយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់។ អង្គការ AFESIP ក៏មានការពាក់ព័ន្ធយ៉ាងញឹកញាប់ផងដែរទៅនឹងការផ្តល់នូវការថែទាំ និងការស្តារនីតិសម្បទារដល់ជនរងគ្រោះ ដោយពុំមានការពាក់ព័ន្ធណាមួយក្នុងការប្តឹងផ្តល់ជាផ្លូវការចំពោះប្រតិបត្តិការសង្គ្រោះនោះទេ។ ក្នុងករណីបែបនេះ ការឆ្មក់ចូលត្រូវបានធ្វើឡើងដោយនគរបាល តាមរយៈការស៊ើបអង្កេតរបស់ពួកគេ ឬរបស់អង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀត។

☐ **<u>បេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)</u>**

បេសកកម្មយុត្តិធម៌អន្តរជាតិប្រើប្រាស់នូវអតីតភ្នាក់ងារអនុវត្តច្បាប់អ្នកស៊ើបអង្កេតឯកជន និងនាយកដ្ឋានកម្មករយុត្តិធម៌ ដោយប្រើនូវឧបករណ៍ទំនើបៗដើម្បីស៊ើបអង្កេត និងអនុវត្តន៍ការឆ្មក់ចូលនិងសង្គ្រោះ។ បន្ទាប់ពីមានការឆ្មក់ចូលជាច្រើនដងក្នុងតំបន់ស្វាយប៉ាកក្នុងឆ្នាំ ២០០៣ និង ២០០៤ ថ្មីៗនេះបេសកកម្មយុត្តិធម៌អន្តរជាតិបានប្រកាសថា ខ្លួនបានសហប្រតិបត្តិការជាមួយអាជ្ញាធរ ដើម្បីធ្វើនូវអ្វីដែលអ្នកដទៃបានព្យាយាមធ្វើអស់រយៈពេលជាច្រើនឆ្នាំមកហើយ ដូចជាការព្យាយាមបង្ក្រាបបណ្តាញជួញដូរមនុស្សនៅប្រទេសកម្ពុជា។

## ៦.៣ ការស្ទង់មតិ

ការស្ទង់មតិ ដែលបានធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាលជាច្រើនបានបង្ហាញអំពីរូបភាពនៃផលប៉ះពាល់មួយចំនួនពីការផ្តល់សេវារកស៊ីផ្លូវភេទ ថែមទាំងអំពីផលប៉ះពាល់ដល់ជីវភាពរស់នៅ និងក្តីសង្ឃឹមរបស់ប្រជាជនដែលត្រូវបានបង្ខំឱ្យធ្វើជាទាសករផ្លូវភេទផងដែរ ។

### □ <u>ក្រុមប្រឹក្សាប្រជាពលរដ្ឋ</u>

ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការគ្រូពេទ្យគ្មានព្រំដែន និងខេមរា គម្រោងអនាគតរបស់ក្រុមប្រឹក្សាប្រជាពលរដ្ឋបាន និងរៀបចំសកម្មភាពនានាអំពី **ការរៀនសូត្រដោយមានការចូលរួមក្នុងសកម្មភាព** (PLA) ជាផ្នែកមួយនៃគម្រោងស្រាវជ្រាវប្រតិបត្តិការដែលមានរយៈពេល ២ឆ្នាំ។ គម្រោងស្រាវជ្រាវនេះបានផ្តោតទៅលើការកសាង និងប្រមែប្រមូលសហគមន៍ក្នុងចំណោមក្មេងស្រីរកស៊ីផ្លូវភេទរស់នៅក្នុងផ្ទះបន ដែលជំពាក់បំណុលគេច្រើនក្នុងតំបន់ស្វាយប៉ាក[៦] ។

លទ្ធផលជាសំខាន់បង្ហាញថា "ក្មេងស្រីរកស៊ីផ្លូវភេទមិនមានបំណងចំណាយពេលកសាងបណ្តាញសហគមន៍ទេ ពីព្រោះពួកគេមានចំណាប់អារម្មណ៍តិចតួច ឬក៏គ្មានសោះក្នុងតំបន់ស្វាយប៉ាក។ ពួកគេបានធ្វើអន្តោប្រវេសន៍ដោយខុសច្បាប់ពីប្រទេសវៀតណាមគ្មានសិទ្ធិ ហើយជាធម្មតាមិនអាចធ្វើទំនាក់ទំនងជាមួយប្រជាពលរដ្ឋខ្មែរក្នុងមូលដ្ឋាន។ ពួកគេមានបំណងធ្វើយ៉ាងណារកលុយឱ្យបានច្រើនយ៉ាងឆាប់រហ័ស តាមដែលអាចធ្វើទៅបានមុនពេលត្រឡប់ទៅប្រទេសវៀតណាមវិញ ទោះបីជាវាមានការរួមភេទដោយមិនមានសុវត្ថិភាពយ៉ាងណាក៏ដោយ។"[៧] អ្នកសរសេររបាយការណ៍នេះ ក៏បានគូសបញ្ជាក់ផងដែរថា ការសិក្សាបង្ហាញថា វគ្គសិក្សាអំពីការរៀនសូត្រដោយមានការចូលរួមក្នុងសកម្មភាពមានសារៈសំខាន់មិនត្រឹមតែដើម្បីប្រមូលទិន្នន័យប៉ុណ្ណោះទេ តែថែមទាំងជាឧបករណ៍ពង្រឹងអំណាចសម្រាប់អ្នករកស៊ីផ្លូវភេទផងដែរ វគ្គសិក្សាទាំងនេះអាចជួយអ្នករកស៊ីផ្លូវភេទឱ្យដោះស្រាយការព្រួយបារម្ភផ្ទាល់ខ្លួនពួកគេដោយអនុញ្ញាតឱ្យពួកគេកសាងការគោរពខ្លួនឯងជំនាញសម្រាប់ជីវិត និងសាមគ្គីភាព។

### □ <u>អង្គការ AIDéTouS</u>

គោលបំណងសំខាន់របស់អង្គការ AIDéTouS គឺដើម្បីកាត់បន្ថយនូវផលអវិជ្ជមានពីវិស័យទេសចរណ៍បែបទំនើបដោយមានបំណងជម្រាបជូនបង្កើតបង្ហាញធ្វើសកម្មភាព និងប្រមែប្រមូលប្រជាពលរដ្ឋតាមសហគមន៍។ ការនៅឆ្ងាយពីការទទួលផលប្រយោជន៍សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ជាក់ស្តែងវិស័យទេសចរណ៍ដ៏ធំមហិមាអាចនាំមកនូវភាពកាន់តែក្រីក្រជាជាងធ្វើអោយមានបានសំរាប់ប្រជាពលរដ្ឋ។ នៅក្នុងវិស័យទេសចរណ៍ផ្លូវភេទ

---

[៦] លទ្ធផលពីការស្ទង់មតិរបស់លោក Baker and al., op. cit.

[7] Baker and al., op. cit។ ទំព័រទី ៤២

គោលដៅនៃការស៊ើបអង្កេតរបស់អង្គការ AIDéTouS គឺដើម្បីកែប្រែកំណើនទេសចរណ៍ផ្លូវភេទទូទាំងពិភពលោក នាពេលបច្ចុប្បន្ន។ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ កំពុងមានការកើនឡើងយ៉ាងខ្លាំងទូទាំងពិភពលោក ជាពិសេស ក្នុងប្រទេសកម្ពុជា ដែលមានភ្ញៀវទេសចរ និងតម្រូវការភ្ញៀវទេសចរបរទេសដែលអង្គការ AIDéTouS បាន ព្យាយាមកំណត់នូវបរិមាណ ដោយដឹកនាំធ្វើការស្ទង់មតិក្នុងកិច្ចសហការជាមួយអង្គការ MDM, MEC, PSF, RACHA និង ខេមរា។

សម្ភាសន៍ផ្សេងៗជាច្រើនបញ្ជាក់ថា តម្រូវការរបស់ភ្ញៀវទេសចរដើម្បីរួមភេទជាមួយកុមារដោយប្រើប្រាស់ ឬមិនប្រើប្រាស់ស្រោមអនាម័យធ្វើឱ្យកើនឡើងអនីតិជនរកស៊ីផ្លូវភេទ និងការទទួលភ្ញៀវតាមតម្រូវការរបស់មេ បន។ នៅពេលបានលក់ព្រហ្មចារីរបស់គេរួចហើយ កុមារទាំងនេះនៅតែធ្វើការក្នុងកន្លែងពេស្យាចារដដែលកត្តា សំខាន់ពីព្រោះកុមារបានបាត់បង់លក្ខណៈរបស់ខ្លួនថា ជាកុមារដែលមិនអាចធ្វើសមាហរណកម្មទៅក្នុងក្រុមគ្រួសារ ដើមរបស់គេវិញបាន ហើយក៏ពីព្រោះបណ្តាញមេបនជាទូរទៅបានរៀបចំប្រព័ន្ធបំណុលដែលឪពុកម្តាយរបស់កុមារ មិនអាចសងវិញរួច លុះត្រាតែកូនរបស់គេធ្វើជាអ្នករកស៊ីផ្លូវភេទបានរយៈពេលច្រើនឆ្នាំសិន។ ជនអនាចារក៏ធ្វើឱ្យ កុមារប្រឈមមុខនឹងជម្ងឺកាមរោគផងដែរ ដែលជាការបន្ថែមនូវការឈឺចាប់ដល់កុមារទាំងផ្លូវចិត្ត និងផ្លូវកាយ រយៈពេលដ៏យូរ។ យោងតាមក្មេងស្រីរកស៊ីផ្លូវភេទនានាបានឱ្យដឹងថា ភ្ញៀវស្វែងរកកុមារព្រហ្មចារី ដោយសារតែ លក្ខណៈធម្មជាតិរបស់ពួកគេចូលចិត្តរួមភេទជាមួយកុមារ ឬក៏ដើម្បីកាត់បន្ថយការប្រឈមមុខនឹងរោគឆ្លង ឬដោយ សារហេតុផលនៃជំនឿ (រក្សាវ័យឱ្យនៅក្មេងប្រយុទ្ធប្រឆាំងនឹងជម្ងឺកាមរោគ...) ដោយគ្មានការព្រួយបារម្ភពីជម្ងឺ កាមរោគដែលអាចឆ្លងបាន។

## ៧. ប្រសិទ្ធផល និងផលប៉ះពាល់នៃកម្មវិធីរបស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលស្តីពី បញ្ហាស្មុគ្រស្មាញ និងអំពើពេស្យាចារក្នុងតំបន់ស្វាយប៉ាក

ការចោទសួរអំពីប្រសិទ្ធភាពនៃការធ្វើអន្តរាគមន៍របស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលលើបញ្ហា ជួញដូរ និងយ៉ាងជាក់ច្បាស់ជាងនេះទៀត លើដំណើរការសង្គ្រោះនឹងគូសបញ្ជាក់នូវការកត់សំគាល់ផ្សេងៗពីគ្នា។ ទី១ ទោះបីជាមានការធ្វើឱ្យមានភាពយុត្តិធមិយ៉ាងណាក៏ដោយ ក៏វាទំនងថា ការអន្តរាគមន៍កម្រិតតូចមានបំណង សង្គ្រោះជនរងគ្រោះបានមួយចំនួនតូចនឹងគ្រាន់តែឈានទៅរកការជំនួសពួកគេ ដោយមនុស្សដែលត្រូវគេជួញដូរ ផ្សេងទៀតប៉ុណ្ណោះ។ ទី២ បញ្ហានៃការជំនួសដ៏លឿននេះមានការពាក់ព័ន្ធគ្នាយ៉ាងខ្លាំង ចំពោះឧបសគ្គនានាដែល រដ្ឋាភិបាលបានជួបប្រទះ ដូចជាត្រូវពង្រឹងការអនុវត្តច្បាប់ដែលមានស្រាប់ ឬបង្កើតវិធានការឱ្យបានគ្រប់គ្រាន់។ ឧទាហរណ៍ បទបញ្ញត្តិដែលចេញដោយអាជ្ញាធរមូលដ្ឋានចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០០២ ដើម្បីបិទតំបន់ ស្វាយប៉ាកឥតមានឥទ្ធិពលណាមួយលើភាពមកញឹកញាប់របស់ភ្ញៀវទេ ប៉ុន្តែភាគច្រើនបានធ្វើអោយកម្រិតជីវភាព

រស់នៅរបស់អ្នករកស៊ីផ្លូវភេទកាន់តែអាក្រក់ឡើង។ ចំណុចកត់សំគាល់ដ៏សំខាន់មួយមួយទៀត គឺការប្រើប្រាស់ទឹកប្រាក់ដើម្បីកេងប្រវ័ញ្ចលើកុមារ ហើយវាជះឥទ្ធិពលដល់ការអនុវត្តន៍ច្បាប់។ ដូច្នេះព័ត៌មានខាងក្រោម ដែលបានប្រមូលនៅក្បែរៗវត្តភ្នំ (សូមមើលបទសម្ភាសន៍នៅក្នុងឧបសម្ព័ន្ធ) ផ្តល់ឱ្យយើងនូវរូបភាពមួយយ៉ាងល្អនៃមន្ទិលថា : កុមារដែលត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទ និងធ្វើពាណិជ្ជកម្មមួយក្រុមមានគ្នាពី ១០ ទៅ ២០ នាក់ មានអាយុរវាងពី ១០ ទៅ ១២ឆ្នាំ បាននាំយកលុយ ១០០០ដុល្លា ក្នុងមួយយប់ទៅឱ្យមេបនរបស់ពួកគេ។ មេបននេះត្រូវចំណាយរវាងពី ២០០ ទៅ ៣០០ ដុល្លា ក្នុងមួយថ្ងៃទៅអោយមន្ត្រីនគរបាលដែលមានតំណែងខ្ពស់។ ការគណនាយ៉ាងរហ័សមួយបង្ហាញថា ក្នុងមួយឆ្នាំ :

- ☆ ប្រាក់ចំណូលនាំចូល ដោយកុមារមួយក្រុមតូចនេះជាអប្បបរមា ៣០០០០០ដុល្លា
- ☆ ប្រាក់ចំណាយសម្រាប់ការការពារពីនគរបាលគឺ ប្រហែលជា ៨០០០០ដុល្លា សម្រាប់រយៈពេលដូចគ្នា។

ពាក់ព័ន្ធទៅនឹងបញ្ហានេះយើងអាចសង្កេតឃើញថា សេដ្ឋកិច្ចនៃអំពើពេស្យាចារដើរតួនាទីយ៉ាងសំខាន់ក្នុងប្រសិទ្ធភាពនៃការអនុវត្តន៍ច្បាប់។ ស្រដៀងគ្នានេះដែរ កង្វះនៃប្រសិទ្ធផលអន្តរាគមន៍របស់អង្គការក្រៅរដ្ឋាភិបាលនឹងមិនត្រូវបានធ្វើឱ្យប្រសើរឡើងទេ បើពុំមានការចាត់វិធានការចំពោះភាពពាក់ព័ន្ធរបស់មន្ត្រីនគរបាលមួយចំនួននោះ។ ប៉ុន្តែវាសំខាន់ណាស់ដើម្បីបញ្ជាក់ថា មិនមែនគ្រប់អង្គភាពនគរបាល ឬបុគ្គលទាំងអស់សុទ្ធតែពុករលួយនោះទេ កម្មវិធី និងកិច្ចខិតខំប្រឹងប្រែងយ៉ាងមុតមាំស្ថិតនៅជាមួយសេចក្តីត្រូវការនៃការយកចិត្តទុកដាក់ និងគាំទ្រពីសាកលលោក។

នៅក្នុងផ្នែកនេះ ដើម្បីបញ្ជាក់ពីការពន្យល់របស់យើងពីមុន យើងនឹងផ្តល់នូវការប៉ានប្រមាណនៃការបិទតំបន់ស្វាយប៉ាក "ជាស្ថាព័រ" និងជោគជ័យតាមរយៈសំភាសន៍ការស៊ើបអង្កេតរបាយការណ៍ និងការស្រាវជ្រាវ។ យើងមានបំណងស្វែងយល់ថា ហេតុអ្វីបានជាវាចំណាយពេលវេលាយូរក្នុងការបិទតំបន់ស្វាយប៉ាកជាស្ថាព័រ?

ចំណុចសំខាន់ៗបួន នឹងត្រូវបានគូសបញ្ជាក់ដើម្បីវាយតម្លៃប្រសិទ្ធិផលនៃវិធានការនេះ។ យើងក៏នឹងមានបំណងផ្តល់នូវការប៉ាន់ប្រមាណនៃការបិទតំបន់ស្វាយប៉ាកនេះផងដែរ តាមរយៈការឆ្មក់ចូល និងឈ្លបមើលរបស់នគរបាលលើបណ្តាញពេស្យាចារ និងជួញដូរលើការរីករាលដាលនៃប្រជាជនរកស៊ីផ្លូវភេទលើជីវិតអ្នកសហគមន៍នេះ និងលើសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀត។

## ៧.១ ការប៉ាន់ប្រមាណនៃផលប៉ះពាល់ពីការឆ្មក់ចូលផ្ទះបនស្ដីពីបណ្ដាញពេស្យាចារ និងជួញដូរក្នុងតំបន់ស្វាយប៉ាក[៨]

ប្រវត្តិនៃអន្តរាគមន៍របស់នគរបាលតាំងពី ខែសីហា ឆ្នាំ ២០០២ ផ្អែកលើព័ត៌មានដែលប្រមូលបានតាមរយៈសហគមន៍ និងយកចិត្តទុកដាក់បន្ថែមទៀតពីផលលំបាកអតីតកាលក្នុងការបិទស្វាយប៉ាក។ ជាអាទិភាពដើម្បីផ្ដល់ព័ត៌មានណាមួយ យើងសូមបញ្ជាក់នៅទីនេះថា អ្នកផ្ដល់ព័ត៌មានរបស់យើងមិនមានព័ត៌មានពេញលេញនោះទេ ហើយអាចទទួលបានព័ត៌មានខ្លះដែលមានការភាន់ច្រឡំ។ ឧទាហរណ៍ ជួនកាលមនុស្សទាំងនេះគិតថា ស្ត្រីរកស៊ីផ្លូវភេទបានទៅ AFESIP ប៉ុន្តែពួកគេមិនបានទៅនោះទេ ប្រហែលជាពួកគេទៅកាន់មជ្ឈមណ្ឌលស្ត្រីមានវិបត្តិកម្ពុជា ឬក៏ប្រហែលជាមនុស្សទាំងនេះគិតថា អង្គការក្រៅរដ្ឋាភិបាលមានការពាក់ព័ន្ធនឹងការឆ្មក់ចូលដែលតាមពិតពួកគេមិនបានពាក់ព័ន្ធទេ។ ចុងក្រោយយើងចង់គូសបញ្ជាក់ឱ្យបានច្បាស់លាស់នៅចំណុចនេះថា ទោះបីជាមានអន្តរាគមន៍របស់នគរបាលជាច្រើនដងក៏ដោយ ក៏ស្វាយប៉ាកនៅតែផ្ដល់កុមារ និងក្មេងស្រីរកស៊ីផ្លូវភេទទៅឱ្យភ្ញៀវបរទេស និងភ្ញៀវក្នុងស្រុកនៅឡើង។ ចុងក្រោយការផ្លាស់ប្ដូរយុទ្ធសាស្ត្ររបស់នគរបាល ឬឆន្ទៈនយោបាយពិតប្រាកដមួយបានតម្រូវជាចាំបាច់ដើម្បីបិទនូវផ្ទះបនទាំងនេះជាស្ថាពរ។

- ☐ ២៧ / ០៨ / ០២ : បទបញ្ញត្តិចេញដោយអភិបាលខ័ណ្ឌឫស្សីកែវបញ្ជា ឱ្យបិទស្វាយប៉ាក
- ☐ ១៧ / ០៨ / ០៣ : នគរបាលអាវុធហត្ថពីទីក្រុងភ្នំពេញ និងខ័ណ្ឌឫស្សី កែវបានធ្វើការឆ្មក់ចូលនៅម៉ោង ៦ព្រឹក នៅផ្ទះបន លេខ១៧។ ក្មេងស្រីប្រាំបីនាក់ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅកាន់ការិយាល័យមជ្ឈមណ្ឌលស្ត្រីមានវិបត្តិកម្ពុជា។
- ☐ ២៥ / ០៨ / ០៣ : នគរបាលពីខ័ណ្ឌឫស្សីកែវបានឆ្មក់ចូលផ្ទះបនលេខ៦ ចាប់បានក្មេងស្រីបួននាក់ ហើយឃុំខ្លួនពួកគេក្នុងស្នាក់ការនគរបាល។
- ☐ ០៣ / ០៩ / ០៣ : នគរបាលបានសង្គ្រោះក្មេងស្រី២២នាក់ ហើយបានបញ្ជូនពួកគេទៅមណ្ឌលអង្គការ AFESIP
- ☐ ១៥ / ១០ / ០៣ : នគរបាលពីទីក្រុងភ្នំពេញបានឆ្មក់ចូលផ្ទះបនលេខ ៥ ឥតមានក្មេងស្រីណាមួយត្រូវបានចាប់ខ្លួនទេ ពីព្រោះក្មេងស្រីទាំងនោះបានគេចខ្លួនមុនពេលនគរបាលមកដល់។
- ☐ ២៤ / ១១ / ០៣ : នគរបាលបានធ្វើការឆ្មក់ចូលមួយផ្សេងទៀតនៅផ្ទះ បនលេខ ៥ នៅម៉ោង ៥ល្ងាច។ ពេលនេះក្មេងស្រីប្រាំនាក់ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅកាន់អង្គការ AFESIP។ ក្មេងស្រីពីរនាក់បានរត់គេចខ្លួនពីនគរបាលដោយលោតតាមសំយាបផ្ទះ (ម្នាក់បានរងរបួសជើង) នគរបាលក៏បានចាប់ខ្លួនភ្ញៀវ

[៨] យើងគ្រាន់តែជជែកអំពីតំបន់ស្វាយប៉ាកនៅទីនេះ ហើយដែលមានតំបន់ភ្លើងពណ៌ក្រហមជាច្រើនផ្សេងៗទៀតក្នុងក្រុងភ្នំពេញដែលការឆ្មក់ចូល និងសង្គ្រោះត្រូវបានធ្វើឡើងផងដែរ។

បីនាក់ផងដែរ (ពួកបច្ចឹមប្រទេសពីរនាក់ និងជនជាតិជប៉ុនម្នាក់)។ ជនជាតិជប៉ុនកំពុងថតវីដេអូសិចជាមួយក្មេងស្រី។

- □ 07 / 12 / 03 : ក្រុមនគរបាលមួយក្រុមតូចមកពីខ័ណ្ឌឫស្សីកែវ បានចូលផ្ទះបនលេខ ១៧ ហើយបានចាប់ខ្លួនមេបនបញ្ជូនទៅទីស្នាក់ការនគរបាល។ មេបនបានបង់លុយចំនួន ៥០ដុល្លា ហើយក៏ត្រូវបានដោះលែងវិញ។
- □ 08 / ១២ / 0៣ : នគរបាលពីរនាក់ពីខ័ណ្ឌឫស្សីកែវ បានចូលមកផ្ទះបនលេខ ២១ នាម៉ោងប្រហែល ៨ល្ងាច ហើយបានចាប់ក្មេងស្រីពីរនាក់ (នៅខណៈពេលដែលក្មេងស្រីទាំងពីនេះកំពុងឈរនៅខាងក្រៅផ្ទះបន) ក្មេងស្រីទាំងនេះបានបង់លុយម្នាក់ ២០ដុល្លា។
- □ ១៨ / ១២ / 0៣ : នគរបាលពីក្រុងភ្នំពេញ និងខណ្ឌឫស្សីកែវ បានចូល ទៅផ្ទះបនលេខ ៦ ម៉ោង ៤ រសៀល។ ជនរងគ្រោះវៀតណាម ប្រាំបីនាក់ ត្រូវបានសង្គ្រោះ ហើយបានបញ្ជូនទៅអង្គការ AFESIP នៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២00៣ តាមរយៈ SKK។ ភ្ញៀវបីនាក់ (១ ជាពួកបច្ចឹមប្រទេស ២នាក់ទៀតជាជនជាតិជប៉ុន) ហើយមេបនក៏ត្រូវបានចាប់ខ្លួនផងដែរ។
- □ 0៥ / ៨ / 0៤ : នគរបាលជាង២0នាក់ពីទីក្រុងភ្នំពេញ និងខ័ណ្ឌឫស្សី កែវបានឆ្មក់ចូលនៅម៉ោង ៩ព្រឹក។ ផ្ទះបនទាំងគ្មានមានមនុស្សទេគ្មានការចាប់ខ្លួន។ ទ្វាផ្ទះបនខ្លះបើកខណៈពេលដែលខ្លះទៀតបិទ : នគរបាលបានប្រើប្រាស់ប្រដាប់កាត់អេឡិចត្រូនិច ដើម្បីទម្លាយទ្វារដែលបិទ។ នគរបាលបានរឹបអូសទូរទស្សន៍ពីរគ្រឿង កង្ហារប្រាំបីគ្រឿង ទូរទឹកកកមួយ នាឡិកាព្យួរជញ្ជាំងមួយ ឧបករណ៍ផ្លុំសក់មួយ កង់តូចមួយ កាបូបដាក់ខោអាវមួយ និងគ្រឿងតុបតែងខ្លួន អង្ករ និងសម្លៀកបំពាក់ជាច្រើន។
- □ ១៨ / 0៨ / 0៤ : នគរបាលមួយក្រុមធំមកពីទីក្រុងភ្នំពេញ និងខ័ណ្ឌឫស្សីកែវ មកដល់ម៉ោង ៣កន្លះរសៀល។ កុមារ និងក្មេងស្រីរកស៊ីផ្លូវភេទទាំងអស់បានគេចខ្លួនចេញពីផ្ទះបន។ នៅខណៈពេលនោះមានផ្ទះបនខ្លះបិទទ្វារ នគរបាលបានប្រើញញួរដើម្បីកម្ទេចផ្ទះបនលេខ ៩។ ផ្ទះបនលេខ ៩ បានរក្សាទុកក្មេងស្រីជាអនីតិជន (អាយុពី ៨ ដល់ ១៣ឆ្នាំ) ប៉ុន្តែគ្មានក្មេងស្រីណាត្រូវបានចាប់ខ្លួនទេ ហើយមេបនបានគេចខ្លួនបាត់។ នគរបាលបានចាប់កូនស្រីមេបនផ្ទះលេខ ៨ (ស្ត្រីរូបនេះបានរៀបការជាមួយមន្ត្រីនគរបាលកម្ពុជា)។ ក្នុងការស្រាវជ្រាវលើផ្ទះបននេះ កាំភ្លើងខ្លីមួយជាកម្មសិទ្ធិរបស់ប្តីស្ត្រីរូបនេះត្រូវបានរកឃើញ ប៉ុន្តែម្ចាស់កាំភ្លើងមិនត្រូវបានចាប់ខ្លួនទេ។
- □ ២0 / 0៨ / 0៤ : នគរបាលជាង១0នាក់ (មកពីខ័ណ្ឌផ្សេងៗ) បានរក្សាការឃ្លាំមើលក្នុងតំបន់ស្វាយប៉ាក។ ពួកគេធ្វើការជាក្រុមដែលមានគ្នា ២នាក់ ដោយយាមនៅខាងក្រៅផ្ទះបន និងតាមច្រកផ្លូវចូលស្វាយប៉ាក។

- ☐ <u>នៅម៉ោង៣រសៀលថ្ងៃទី ២០ ខែសីហា</u> : ភ្នាក់ងារសម្ងាត់របស់ក្រុមបេសកកម្មយុត្តិធម៌អន្តរជាតិបានសុំឱ្យអ្នករត់ម៉ូតូឌុបម្នាក់ឱ្យឌុមក្មេងស្រី ពីរនាក់ ពីស្វាយប៉ាកមកកាន់សណ្ឋាគារក្នុងទីក្រុងភ្នំពេញ។ ម្នាក់ឈ្មោះ "ទៀន" អាយុ១៨ឆ្នាំ ធ្វើការក្នុងផ្ទះបនលេខ ៦។ ម្នាក់ទៀតឈ្មោះ "លី" អាយុ១៣ឆ្នាំ ដែលបន្ទាប់ពីលក់ព្រហ្មចារីរបស់នាងរួចហើយ បានធ្វើការនៅខាងក្រៅ (ជាក្មេងស្រីរកស៊ីផ្លូវភេទដោយប្រយោល)។ នៅពេលមកដល់សណ្ឋាគារនោះ ក្មេងស្រីទាំងពីរនាក់នោះត្រូវបានចាប់ខ្លួន ហើយអ្នករត់ម៉ូតូឌុបត្រូវបានឃុំខ្លួនដោយមន្ត្រីក្រសួងមហាផ្ទៃ។ គ្មានព័ត៌មានណាមួយត្រូវបានចេញផ្សាយអំពីក្មេងស្រីទាំងពីរនេះទេ។
- ☐ <u>២១-២៣ / ០៨ / ០៤</u> : នគរបាលបានរក្សាការឃ្លាំមើលសកម្មភាពនៅក្នុងតំបន់ស្វាយប៉ាក។ នគរបាលបានដេកក្នុងការិយាល័យសង្កាត់ ដោយប្តូរវេនគ្នា។
- ☐ <u>២៤ / ០៨ / ០៤</u> : ប៉ូលីសនៅតែមានវត្តមានក្នុងតំបន់ស្វាយប៉ាក។ នគរបាលពីរនាក់មកកាន់ការិយាល័យអង្គការខេមរា ដើម្បីពិភាក្សាជាមួយបុគ្គលិក។ នគរបាលបានសាកសួរក្មេងស្រីដែលមានវត្តមាននៅទីនោះថា តើពួកគេបានមកគ្លីនិកដើម្បីពិគ្រោះយោបល់ដែរឬទេ។

ការសន្និដ្ឋានខ្លីមួយនៃអន្តរាគមន៍របស់នគរបាលផ្សេងៗទាំងនេះបង្ហាញ ថា :

- ➪ បទបញ្ញត្តិដែលបានចេញដោយមន្ត្រីខ័ណ្ឌឫស្សីកែវនៅខែសីហា ឆ្នាំ ២០០២ មិនមានឥទ្ធិពលណាមួយលើភាពមកញឹកញាប់របស់ភ្ញៀវទេ។ ដូចបានអះអាងក្នុងការស្ទង់មតិរបស់អង្គការ AIDéTouS ការមកញឹកញាប់នេះកំពុងនៅតែមានការកើនឡើង ក្រោយពីមានការអនុវត្តន៍បទបញ្ញត្តិនេះដើម្បីស៊ើបអង្កេតការកើនឡើង ២៩.៧% រវាងខែសីហា និងខែធ្នូ ឆ្នាំ ២០០២។ លើសពីនេះទៅទៀត បទបញ្ញត្តិនេះភាគច្រើនប៉ះពាល់យ៉ាងខ្លាំងលើកម្រិតជីវភាពរស់នៅរបស់ជនរកស៊ីផ្លូវភេទ។ ទ្វារទាំងអស់ត្រូវបានបិទ ហើយក្មេងស្រីរកស៊ីផ្លូវភេទត្រូវបានបិទ។ មានតែកុមារដែលបាន និងកំពុងលេងតាមផ្លូវ និងកំពុងរង់ចាំជាចំហរនូវភ្ញៀវដ៏មានសក្តានុពលប៉ុណ្ណោះ។
- ➪ ដូចដែលបានអះអាងខាងលើ ប្រសិនបើភ្ញៀវត្រូវបានចាប់ខ្លួននៅក្នុងតំបន់ស្វាយប៉ាក គ្មានការតាមដានណាមួយត្រូវបានដឹងច្បាស់នៅឡើយទេរហូតដល់ពេលនេះ។ ជាក់ស្តែង យើងបានជួបនៅជនជាតិជប៉ុន ដែលត្រូវបានចាប់ខ្លួនកាលពីខែវិច្ឆិកា ឆ្នាំ ២០០៣ នៅបារម៉ាថេនី។
- ➪ មានអន្តរាគមន៍តិចតួចប៉ុណ្ណោះក្នុងចំណោមអន្តាគមន៍ទាំងអស់ឈានទៅរកចាប់ខ្លួនមេបន ឬម្ចាស់ផ្ទះបន ប៉ុន្តែភាគច្រើន គឺក្មេងស្រីរកស៊ីផ្លូវភេទ។ ជារឿយៗពួកគេមិនត្រូវបានចោទប្រកាន់ ហើយជាធម្មតាពួកគេសូកប៉ាន់ដើម្បីរួចខ្លួនមុនពេលចូលតុលាការ។ យោងទៅអង្គភាពនគរបាលដែលទទួលបន្ទុកផ្នែកប្រតិបត្តិការបានឱ្យដឹងថា នៅពេលមេបន ឬម្ចាស់ផ្ទះបនត្រូវបានចាប់ខ្លួនចន្លោះ ៥០០ ទៅ

៨០០ដុល្លា សម្រាប់មេបនហើយចន្លោះពី ១០០០ ទៅ ២០០០ ដុល្លា សម្រាប់ម្ចាស់ផ្ទះបន ដើម្បីជួយពួកគេឱ្យមានសេរីភាពឡើងវិញ។ ចំពោះក្មេងស្រីរកស៊ីផ្លូវភេទនឹងត្រូវបង់ថ្លៃចន្លោះពី ២០ ទៅ ៥០ដុល្លា។

⇨ វាកើតឡើងយ៉ាងច្បាស់ក្នុងការពិពណ៌នាអំពី អន្តរាគមន៍ទាំងនេះ ដែលព័ត៌មានសម្ងាត់មានការលេចចេញពីខាងក្នុង និងរវាងនាយកដ្ឋាននគរបាលផ្សេងៗគ្នា។ ឱកាសជាច្រើនផ្ទះបនទទេស្អាតនៅពេលនគរបាលឆ្មក់ចូល ហើយមេបន ឬម្ចាស់ផ្ទះបនបានគេចខ្លួនបាត់មុនទៅហើយ។ ការនេះបង្ហាញពីភាពគ្មានប្រសិទ្ធភាពនៃការឆ្មក់ចូលរបស់នគរបាល ដែលបន្តចោទសួរជាបញ្ហាសម្រាប់ការអភិវឌ្ឍន៍នៃដៃគូរវាងអង្គការក្រៅរដ្ឋាភិបាល និងនគរបាលដើម្បីប្រយុទ្ធប្រឆាំងនឹងការរំលោភផ្លូវភេទលើកុមារ។

⇨ រាល់សម្ភាសន៍ទាំងអស់ក្នុងចំណោមក្មេងស្រីរកស៊ីផ្លូវភេទ និងម្ចាស់ផ្ទះបនបានអះអាងថា មាននគរបាលដែលប្រកបមុខរបរពេស្យាចារទុច្ចរិត។ សកម្មភាពនេះអាចស្ថិតនៅក្រោមការនាំចេញលុយ ឬការនាំចូលទំនិញខុសច្បាប់។ ឧទាហរណ៍ ក្នុងការឆ្មក់ចូលរបស់នគរបាលតាមផ្លូវស៊ីសុវត្ថិ នគរបាលបានរឹបអូសយករបស់របរទាំងអស់របស់ក្មេងស្រីរកស៊ីផ្លូវភេទ។ ប៉ូលីសបានចាប់មេបនម្នាក់ដោយសុំឱ្យគាត់បង់ ៣០ ដុល្លា។ នៅពេលដែលគាត់មិនមានលុយ គាត់ត្រូវបានបញ្ជូនទៅទីស្នាក់ការនគរបាល។ ចុងក្រោយនគរបាលបានដោះលែងគាត់ក្រោយពីបានរឹបអូសយកស្បែកជើងរបស់គាត់។

⇨ ពាក់ព័ន្ធទៅនឹងសម្ភាសន៍មួយជាមួយបុរសម្នាក់ (មើលឧបសម្ព័ន្ធ) ធ្វើឡើងនៅ "វត្តភ្នំ" យើងបានរកឃើញថា ម្ចាស់ផ្ទះបនពីមុនដែលមានក្មេងប្រុស និងក្មេងស្រីជាអតិថិជននៅតែបន្តសកម្មភាពរកស៊ីផ្លូវភេទ។ យើងបានដឹងថា គាត់កំពុងកេងប្រវ័ញ្ចលើកុមារប្រមាណ ២០នាក់ ហើយអាចរកលុយបានប្រហែល ១០០០ដុល្លា ក្នុងមួយយប់។ ហើយគាត់ក៏ត្រូវបង់ជារៀងរាល់ថ្ងៃប្រហែល ២០០ ទៅ ៣០០ ដុល្លា ទៅឱ្យមន្ត្រីនគរបាលដែលមានឋានៈខ្ពស់ និងនគរបាលអាវុធហត្ថដើម្បីការពារ។

⇨ ជាចុងក្រោយការអនុវត្តន៍នៃប្រព័ន្ធឃ្លាំមើល ដែលបានផ្តត់ផ្តង់ផ្នែកហិរញ្ញវត្ថុដោយបេសកកម្មយុត្តិធម៌អន្តរជាតិចាប់តាំងពីខែសីហា ឆ្នាំ ២០០៤ មកនោះបានឈានទៅរកការបិទតំបន់ស្វាយប៉ាកជាស្ថាពរ។

⇨ ផលវិបាកមួយផ្សេង គឺភាពខុសគ្នានៃការវិនិច្ឆ័យ ឬការឱ្យតម្លៃនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារដោយម្ចាស់ផ្ទះបន។ នៅទួលគោកម្ចាស់ផ្ទះបនលេខ ១២ ពីមុនមានបំណងទូរស័ព្ទហៅនគរបាលប្រសិនបើគាត់ឃើញជនអនាចារ ឬផ្ទះបនដែលលក់កុមារ។ ក៏ប៉ុន្តែតួនាទីនេះនាំមកនូវតម្លៃសេដ្ឋកិច្ចនៃការបិទតំបន់ស្វាយប៉ាកច្រើនជាងការយល់ដឹងពីបញ្ហារំលោភកុមារ។

## ៧.២ ការប៉ាន់ប្រមាណលើផលប៉ះពាល់នៃការឆ្មក់ចូលផ្ទះបន ស្តីពីការរីករាលដាលនៃតួអង្គពេស្យាចារពីតំបន់ស្វាយប៉ាក និងផលវិបាករបស់វាចំពោះអ្នករកស៊ីផ្លូវភេទ

មានផលប៉ះពាល់សំខាន់ៗចំនួនបីមកពីនគរបាល និងអង្គការក្រៅរដ្ឋាភិបាល ដែលបានជួយឱ្យមានការឆ្មក់ចូលក្នុងតំបន់ស្វាយប៉ាក។ ទី១ ជាដំបូងខណៈពេលនេះ តំបន់ស្វាយប៉ាកនៅតែត្រូវបានបិទដោយជោគជ័យនៅឡើយ។ ទីពីរ មានផលប៉ះពាល់មួយលើការចែកចាយតំរូវការ និងបណ្តាញរបស់វា។ ទីបី យើងអង្កេតផលប៉ះពាល់មួយលើការផ្គត់ផ្គង់ និងការរីករាលដាលរបស់វា។ ជាក់ស្តែងការឆ្មក់ចូលដោយនគរបាលផ្សេងៗគ្នាបានបង្កើតឱ្យមានបរិយាកាសសង្ស័យក្នុងចំណោមមេបន និងបណ្តាញចាត់តាំងរបស់ភ្ញៀវ។ ក្រុមជនជាតិជប៉ុន និងចិនបានផ្លាស់ប្តូរតិរិយាបទរបស់ពួកគេយ៉ាងលឿន ដើម្បីបង្កើតនូវប្រព័ន្ធចែកចាយមួយ ដោយការប្រើប្រាស់ទូរស័ព្ទទំនាក់ទំនងផ្ទាល់ទៅកាន់សណ្ឋាគារ និងផ្ទះសំណាក់។ តាមសំណើរបស់ភ្ញៀវ អ្នកកណ្តាលទាក់ទងម្ចាស់ផ្ទះបនឱ្យរៀបចំការជួញដូរមនុស្សមនុស្ស ឬលក់ព្រហ្មចារី។ ដូចដែលយើងបានអង្កេតនៅខែមករា ភ្ញៀវខ្លះនៅតែទៅកាន់ស្វាយប៉ាក ដែលជាកន្លែងមេបនអាចប្តូរយុទ្ធសាស្ត្រគេជាថ្មី។ម្យ៉ាងវិញទៀត ក្មេងស្រីរកស៊ីផ្លូវភេទប្រហែលជា ២០០នាក់ និងកន្លែងម៉ាស្សាចំនួន ៥០ បានផ្លាស់ប្តូរពីតំបន់ស្វាយប៉ាកតាំងពីការបិទមក។ ការផ្លាស់ប្តូរទាំងនោះរួមមានទៅទីក្រុងភ្នំពេញ ក្រុងសៀមរាប ខេត្តកំពត ព្រំដែនថៃ ហើយ ខ្លះទៀតបានបានវិលត្រឡប់ទៅកាន់ប្រទេសវៀតណាមវិញ។ ប៉ុន្តែយើងក៏បានអង្កេតចលនាក្មេងស្រីរកស៊ីផ្លូវភេទខ្មែរ ដែលពីមុនមាននៅតាមផ្លូវជាតិលេខ ១ ដោយបើកកន្លែងម៉ាស្សា និងផ្ទះបន។

តារាងខាងក្រោមបង្ហាញនូវការចែកចាយក្មេងស្រី និងកុមាររកស៊ីផ្លូវភេទបែបថ្មីមួយ និងការអភិវឌ្ឍន៍នៃតំបន់ថ្មីៗមួយចំនួនជាតំបន់អនាចារ។

**តារាងទី ៣ : ការចែកចាយអ្នករកស៊ីផ្លូវភេទដែលកំពុងតែរីករាលដាល**

| ចំនួនផ្ទះបន | ទីតាំង |
|---|---|
| ១ | ដូនឡែម នៅព្រំដែនថៃ (ខេត្តបាត់ដំបង) |
| ៤ | ភ្នំពេញ តាមផ្លូវលេខ ៦៣ |
| ៥ | ភ្នំពេញ នៅម៉ុំវិត្តភ្នំ |
| ៦ | សៀមរាប តាមផ្លូវលេខ ៦ |
| ៨ | ក្មេងស្រីរកស៊ីផ្លូវភេទទាំងអស់បានចល័តទៅតំបន់ផ្សេងៗ |
| ៩ (កុមារ) | ភ្នំពេញ ម៉ុំវិត្តភ្នំ |

| | |
|---|---|
| ១០ | ភ្នំពេញ នៅទួលគោគ |
| ១២ | ភ្នំពេញ នៅទួលគោគ |
| ១៤ | ភ្នំពេញ នៅបារប៉ាធីនី |
| ១៦ ( កុមារ) | ភ្នំពេញ ម៉ុវត្តភ្នំ និង សៀមរាប តាមផ្លូវលេខ ៦ |
| ១៧ | ភ្នំពេញ |
| ២០ | ប្តូរទីតាំងទៅខេត្តកំពតនៅខែធ្នូ ឆ្នាំ ២០០៤ |
| ២១ | សៀវរាប តាមផ្លូវលេខ ៦ |
| ២២ | សៀវរាប តាមផ្លូវលេខ ៦ |

ការបញ្ចប់សកម្មភាពដែលមិនអាចខានបាននៅក្នុងតំបន់ស្វាយប៉ាក និងមានផលប៉ះពាល់ដោយមិនអាចជៀសរួចលើកម្រិតជីវភាពរស់នៅរបស់ប្រជាជនរកស៊ីផ្លូវភេទ ប៉ុន្តែក៏ប៉ះពាល់ផងដែរលើការរកស៊ីជំនួញខុសច្បាប់ទាំងនេះ។ ការផ្លាស់ប្តូរទាំងនេះអាចបង្ហាញពីកម្រិតសុខមាលភាព និងសេដ្ឋកិច្ច។

ទី ១ តំបន់ស្វាយប៉ាកបាន និងកំពុងប្រឈមមុខនឹងការគាបសង្កត់យ៉ាងខ្លាំងពីអង្គភាពនគរបាល តាមរយៈការឆ្មក់ចូល ឬសំណើស្របច្បាប់ ឬ "ខុសច្បាប់"។ ឧទាហរណ៍ នគរបាលក្នុងស្រុកដាក់បញ្ជាថា ផ្ទះបនទីមួយៗត្រូវតែបង់ ២០ដុល្លា ក្នុងមួយខែសម្រាប់ស្រីរកស៊ីផ្លូវភេទម្នាក់ៗ។ បន្ថែមពីនេះទៅទៀត បញ្ហានេះបង្កើតនូវប្រព័ន្ធពន្ធដា នគរបាលខ្លះប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីទាថ្លៃសេវាកម្ម ឬភេសជ្ជៈជាដើម។ ការបដិសេធនីណាមួយជាទូរទៅត្រូវបានអនុវត្តនី ដោយអន្តរាគមន៍របស់នគរបាលនៅថ្ងៃបន្ទាប់។

ទី ២ ដូចដែលយើងបានបញ្ជាក់រួចហើយ ការបិទតំបន់ស្វាយប៉ាកបានបង្កើតឱ្យមានចលនាមួយ ហើយនិងការចែកចាយអ្នករកស៊ីផ្លូវភេទបែបថ្មី និងទីតាំងថ្មីៗទៀត។ មួយចំនួនក្នុងតំបន់ថ្មីទាំងនេះភាគច្រើនក្នុងក្រុងសៀមរាបទាំងម្ចាស់ផ្ទះបន និងក្មេងស្រីរកស៊ីផ្លូវភេទប្រកាសថា កម្រិតជីវភាពរស់នៅ និងលក្ខខណ្ឌការងារមានភាពប្រសើរជាងតំបន់ស្វាយប៉ាកពីព្រោះមិនមានការរំខាន ឬការចាប់ខ្លួនពីនគរបាល។ នៅទួលគោគ ប្រសិនបើនគរបាលនៅតែមកប្រមូលលុយជារៀងរាល់ថ្ងៃជូនកាល ១០០០០រៀល ជូនកាល ៥០០០រៀល ប្រជាជនដែលត្រូវបានធ្វើសំភាសន៍គិតថា ជីវិតមានសុវត្ថិភាពជាងមុនពីព្រោះមិនមានការឆ្មក់ចូល។

ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើការរំខាននគរបាលហាក់បីដូចជាមានភាពកាន់តែទន់ខ្សោយក្នុងតំបន់ដទៃទៀត ការផ្លាស់ប្តូរមួយចំនួនផ្សេងទៀត ដែលត្រូវបាននាំមកដោយការផ្លាស់ប្តូរបែបបង្ខំទាំងនេះ គួរតែជា

សញ្ញាណមួយសម្រាប់ការវិលត្រឡប់ចូលស្វាយប៉ាកវិញយ៉ាងលឿន។ ដែលគួរអោយភ្ញាក់ផ្អើលគឺថា ទោះបីជាមានបញ្ហាជាច្រើនខុសៗគ្នាជាមួយនគរបាលក្នុងតំបន់ស្វាយប៉ាក ដូចបានពិពណ៌នាខាងលើក៏ដោយ ក៏នៅតែមានញាតិសណ្ដាន និងមិត្តភ័ក្ដកំពុងរស់នៅទីនោះនៅឡើយ ក្មេងស្រីមួយចំនួនរំពឹងថា នឹងវិលត្រឡប់មកវិញឱ្យបានឆាប់តាមតែអាចធ្វើទៅបាន។ ហេតុផលផ្សេងមួយទៀតនៃការវិលត្រឡប់មកវិញ គឺតម្លៃផ្នែកហិរញ្ញវត្ថុនៃទីតាំងថ្មី។ ជាទូរទៅម្ចាស់ផ្ទះបនមានផ្ទះផ្ទាល់ខ្លួន ពួកគេក្នុងតំបន់ស្វាយប៉ាក ហើយតម្លៃការជួលផ្ទះថ្មី និងការចំណាយនៅក្រុងសៀមរាប និងភ្នំពេញមានតម្លៃខ្ពស់ជាងពីមុនខ្លាំង។ ឧទាហរណ៍ នៅតំបន់ស្វាយប៉ាកតម្លៃអគ្គិសនីគឺ ៣៥០ រៀលក្នុងមួយគីឡូវ៉ាត់ ប្រៀបធៀបនឹង ២៥០០រៀល ក្នុងក្រុងភ្នំពេញតាមផ្លូវស៊ីសុវត្ថិសម្រាប់កន្លែងម៉ាស្សា។ តម្លៃទឹកក៏ថ្លៃច្រើនជាងផងដែរ។

ជាចុងក្រោយ ពាក់ព័ន្ធទៅនឹងសមាសធាតុដូចបានពិពណ៌នាខាងលើ ការរកចំណូលផ្នែកហិរញ្ញវត្ថុថ្មីមានលក្ខណៈសំខាន់ច្រើន ឬតិចអាស្រ័យទៅលើទីតាំងថ្មី។ ពួកគេបង្កើនតម្លៃគុណនឹងពីរដងក្នុងខេត្តសៀមរាបសម្រាប់ជនបរទេសដែលកើនពី ៥ដុល្លា ទៅ ១០ដុល្លា។ ផ្ទុយទៅវិញនៅក្នុងតំបន់ទួលគោកគ្មានភ្ញៀវជាជនបរទេសទៀតទេដែលឈានទៅរកការធ្លាក់ចុះប្រាក់ចំណូល។ ដូច្នេះ ប្រសិនបើតំបន់ថ្មីនឹងមានប្រសិទ្ធភាពលើកម្រិតប្រាក់ចំណូលសុខមាលភាព និងភ្ញៀវច្រើន ការសម្រេចវិលត្រឡប់ទៅកាន់តំបន់ស្វាយប៉ាកវិញនឹងពឹងផ្អែកទៅលើកត្តាគ្រួសារចំពោះប្រជាជនរកស៊ីផ្លូវភេទ ឬកត្តាសេដ្ឋកិច្ចសម្រាប់មេបន។

## ៧.៣ ការប៉ាន់ប្រមាណលើផលប៉ះពាល់នៃឆ្នក់ចូល និងការបិទផ្ទះបនស្តីពី ជីវិតអ្នកសហគមន៍ក្នុងតំបន់ស្វាយប៉ាក

ទិន្នន័យទាំងអស់ក្នុងផ្នែកខាងក្រោម ទទួលបានមកពីការស្ទង់មតិតូចមួយក្នុងចំណោម ៣០គ្រួសារ នៃភូមិស្វាយប៉ាក (១០%នៃចំនួនគ្រួសារសរុប)។ ការស្ទង់មតិនេះត្រូវបានធ្វើឡើងនៅខែមករា ឆ្នាំ ២០០៥ ដើម្បីទទួលអារម្មណ៍របស់អ្នកភូមិ និងការវាយតម្លៃអំពីផលវិបាកលើកម្រិតជីវភាពរស់នៅរបស់ពួកគេ ក្រោយពីការបិទតំបន់ស្វាយប៉ាក : ដោយដឹងថា ប្រជាជននេះទទួលបានផលប្រយោជន៍ដោយប្រយោលពីរបរពេស្យាចារ។ មនុស្ស ៣០នាក់ ដែលត្រូវបានធ្វើសំភាសន៍មានអាយុជាមធ្យម ៤៣ ឆ្នាំ ហើយពាក់កណ្ដាលមានអាយុ ៤២ ឆ្នាំ (អប្បបរមា=២៩ អតិបរិមា=៥៧)។

**តារាង ទី៤ : សញ្ជាតិ និងភេទរបស់ប្រជាជនដែលត្រូវបានធ្វើសំភាសន៍**

| ភេទ / សញ្ជាតិ | ស្រី | ប្រុស | សរុប |
|---|---|---|---|
| ខ្មែរ | ៩ | ៦ | ១៥ |
| យួន | ១២ | ៣ | ១៥ |
| **សរុប** | ២១ | ៩ | ៣០ |

ប្រសិនបើប្រជាជន ដែលត្រូវបានធ្វើសំភាសន៍ដែលពាក់កណ្ដាលជាជនកម្ពុជា ហើយពាក់កណ្ដាលទៀតជាជនជាតិយួន ការបែងចែកទីកន្លែងកំណើតបង្ហាញថា ចំនួនមួយក្រុមធំស្មើនឹង ២៣,៣% កើតនៅប្រទេសយួន ហើយ ១០% ទៀតជាខ្មែរមកពីកម្ពុជាក្រោម។

បញ្ហាសំខាន់គឺដើម្បីដឹងអំពីអារម្មណ៍របស់ប្រជាជន ហើយ ៨៣,៣% ក្នុងចំណោមពួកគេគិតថា ការបិទតំបន់ស្វាយប៉ាកមានផលលំបាកលើជីវិតរបស់គេ។ បញ្ហានេះមានបំណងចង់ដឹងថា តើគ្រួសារទាំងនោះប្រឈមមុខនឹងការផ្លាស់ប្តូរ ឬអត់ និងមូលហេតុ។ ជាឧទាហរណ៍ ក្នុងខេត្តសៀមរាប យើងបានជួបមនុស្សមួយចំនួនធំដែលពីមុនមានទីលំនៅក្នុងតំបន់ស្វាយប៉ាកពីអ្នករត់ម៉ូតូឌុបទៅកាន់ស្រីរកស៊ីផ្លូវភេទ អ្នកលក់កាហ្វេ និងផ្សេងៗទៀត។ ការវាយតម្លៃដ៏ខ្លីមួយបានបង្ហាញនូវការផ្លាស់ប្តូរទីលំនៅរបស់មនុស្សចំនួន ១០០នាក់ ពីស្វាយប៉ាកទៅកាន់ខេត្តសៀមរាបដោយមានទិន្នន័យបញ្ជាក់ដែលបានធ្វើឡើងនៅតំបន់ស្វាយប៉ាក។

ប្រសិនបើ ៨៣,៣% នៃចំនួនប្រជាជននេះធ្វើពុតជាប្រឈមមុខនឹងការផ្លាស់ប្តូរហេតុផលដែលបានអះអាងដោយពួកគេគឺជាការធ្លាក់ចុះយ៉ាងខ្លាំងនូវចំនួនភ្ញៀវ។ ជាផលវិបាក ៤៣,៣% មានសមាជិកម្នាក់ ឬច្រើននាក់ដែលបានចាកចេញពីភូមិដើម្បីស្វែងរកការងារធ្វើនៅទីក្រុងភ្នំពេញ ឬកន្លែងផ្សេងទៀត។

**តារាងទី ៥ : ការវាយតម្លៃលើការចាកចេញរបស់សមាជិកគ្រួសារ**

| តើសមាជិកគ្រួសាប៉ុន្មាននាក់ដែលបានចាកចេញពីភូមិដើម្បីរកការងារថ្មីធ្វើ | ជាញឹកញាប់ | ភាគរយ |
|---|---|---|
| 0 | ១៧ | ៥៦,៧ % |
| ១ | ៧ | ២៣,៣ % |

| | | |
|---|---|---|
| ២ | ១ | ៣.៣ % |
| ៣ | ៣ | ១០ % |
| ៤ | ១ | ៣.៣ % |
| ៧ | ១ | ៣.៣ % |
| សរុប | ៣០ | ១០០ % |

ប្រាក់ចំណូល មានការធ្លាក់ចុះយ៉ាងខ្លាំងពាក់ព័ន្ធទៅនឹងការបិទការរកស៊ីផ្លូវភេទ និងការធ្លាក់ចុះចំនួនភ្ញៀវឈានទៅរកការផ្លាស់ប្តូរក្នុងការចំណាយប្រចាំថ្ងៃ និងការកើនឡើងជាទូរទៅនៃបំណុល។ ជាក់ស្តែងចំនួនប្រាក់ចំណូលក្នុងមួយថ្ងៃមានការធ្លាក់ចុះពី ៥២៥០០ រៀល ក្នុងមួយថ្ងៃរហូតមកនៅត្រឹមតែ ១៧០០០ រៀលក្នុង១ថ្ងៃបន្ទាប់ពីការបិទតំបន់ស្វាយប៉ាកមក។ ការធ្លាក់ចុះនៃប្រាក់ចំណូលនេះមានការពាក់ព័ន្ធរហូតដល់ ២៥គ្រួសារ ក្នុងចំណោម ៣០ គ្រួសារ ហើយមានឥទ្ធិពលយ៉ាងខ្លាំងទៅលើប្រាក់ចំណូលប្រចាំថ្ងៃ។ ជាផលវិបាកគ្រួសារទាំងនោះគឺមានការកាត់បន្ថយប្រាក់ចំណាយប្រចាំថ្ងៃពី ១៥៩០០ រៀល ក្នុងមួយថ្ងៃមកត្រឹមតែ ១១៥០០ រៀល ក្នុងមួយថ្ងៃ។ ប៉ុន្តែការចំណាយទាំងនេះភាគច្រើនសម្រាប់បង់ថ្លៃសាលា និងអាហារ។ ជាអកុសលការកាត់បន្ថយផ្នែកថវិកានេះនឹងមានផលប៉ះពាល់ទៅដល់ការសិក្សារបស់កុមារ។ ប្រសិទ្ធភាពទី២ គឺមានតុល្យភាពចំពោះការធ្លាក់ចុះនៃប្រាក់ចំណូលនេះជាមួយ និងការវិនិយោគថ្មីដើម្បីចាប់ផ្តើមរកស៊ីថ្មី ឬក៏ធ្វើឱ្យគុណភាពសេវាកម្មប្រសើរឡើង (កៅអីថ្មី តុថ្មី សម្រាប់បើកហាងកាហ្វេ)។ ប៉ុន្តែការវិនិយោគថ្មីទាំងនេះធ្វើឱ្យគ្រួសារកើននូវប្រាក់បំណុល។ តាមពិតទៅកម្រិតនៃប្រាក់បំណុលមធ្យមមាន ១០១៦ដុល្លា មុនពេលបិទស្វាយប៉ាកដោយបង្ហាញថា មានតែ ១០% នៃប្រជាជនដែលត្រូវបានធ្វើសំភាសន៍ប៉ុណ្ណោះដែលជំពាក់បំណុលគេជាមធ្យម ១៨១ដុល្លា ក្រោយពីបិទដែលស្មើនឹង ៥៦,៧% នៃប្រជាជនដែលត្រូវបានធ្វើសំភាសន៍។

**តារាងទី ៦ : កម្រិតបំណុលនៅស្វាយប៉ាក**

| កម្រិតបំណុល | ជាញឹកញាប់ | ភាគរយ |
|---|---|---|
| ០ | ១៣ | ៤៣,៣ % |
| ១៧ | ១ | ៤៣,៣ % |
| ២៥ | ១ | ៣,៣ % |
| ៣០ | ១ | ៣,៣ % |
| ៥០ | ១ | ៣,៣ % |
| ១០០ | ២ | ៦,៧ % |

| | | |
|---|---|---|
| ១១០ | ១ | ៣,៣ % |
| ១៥០ | ១ | ៣,៣ % |
| ២០០ | ៣ | ១០ % |
| ២៥០ | ១ | ៣,៣ % |
| ៣០០ | ១ | ៣,៣ % |
| ៤០០ | ១ | ៣,៣ % |
| ៥០០ | ១ | ៣,៣ % |
| ៨០០ | ១ | ៣,៣ % |
| ២០០០ | ១ | ១០០ % |
| សរុប | ៣០ | |

មុនពេលបិទតំបន់ស្វាយប៉ាក គ្រួសារពីរជំពាក់បំណុលគេដែលបានខ្ចីលុយ (១០០០ ដុល្លា និង ២០០០ ដុល្លា) សម្រាប់សាងសង់ផ្ទះ។ ក្រោយពីការបិទការបែងចែកទៅលើគ្រួសារដែលជំពាក់បំណុលគេធំបំផុត ហើយពាក់ព័ន្ធជាង ៥០% នៃប្រជាជនដែលត្រូវបានធ្វើសំភាសន៍។ ២៦,៧% នៃគ្រួសារដែលបានធ្វើសំភាសន៍បានខ្ចីលុយគេដើម្បីប្រកបមុខជំនួញថ្មី។

ប៉ុន្តែប្រសិនបើការបិទស្វាយប៉ាកមានផលប៉ះពាល់លើកម្រិតប្រាក់ចំណូល វាក៏ជារឿងមួយដែលគួរឱ្យចាប់អារម្មណ៏ផងដែរ ដើម្បីវិភាគលើការវិនិច្ឆ័យរបស់ប្រជាជនដែលពាក់ព័ន្ធនឹងផលប៉ះពាល់ផលប្រយោជន៏របស់ខ្លួនឬក៏អត់។ ដែលគួរឱ្យចាប់អារម្មណ៏គឺថា ប្រជាជនដែលបានធ្វើសំភាសន៏ត្រូវបានបែងចែកស្មើរគ្នារវាងការធ្លាក់ចុះកម្រិតប្រាក់ចំណូល និងការបញ្ចប់សកម្មភាពដែលធ្វើឱ្យខូចមុខមាត់នៃតំបន់រស់នៅរបស់ពួកគេ។ លើសពីនេះទៅទៀត ប្រសិនបើអំពើពេស្យាចារនៅក្នុងតំបន់ស្វាយប៉ាកត្រូវបានចាត់ទុកជាបាតុភូតនៃជនជាតិយួននោះ មិនមានទំនាក់ទំនងរវាងសញ្ជាតិនៃអ្នកឆ្លើយតប និងខ្លឹមសារនៃចម្លើយរបស់គេទេ។

**តារាងទី៧ : ការកោតសសើរអំពីការបិទតំបន់ស្វាយប៉ាក**

| តើបិទស្វាយប៉ាកល្អឬទេ? / សញ្ជាតិ | យល់ព្រម | មិនយល់ព្រម | សរុប |
|---|---|---|---|
| ខ្មែរ | ៨ | ៧ | ១៥ |
| យួន | ៧ | ៨ | ១៥ |
| សរុប | ១៥ | ១៥ | ៣០ |

ចំណុចមួយបន្ថែមទៀត ជាធម្មតាមិនត្រូវបានអះអាងដោយអង្គការក្រៅរដ្ឋាភិបាលទេ គឺការពេញចិត្ត របស់អ្នកភូមិលើផលប៉ះពាល់នៃការបិទស្វាយប៉ាក ទាក់ទងបញ្ហាការប្រើប្រាស់គ្រឿងញៀន។ ស្របទៅនឹងសេវាពេស្យាចារ ទីផ្សារគ្រឿងញៀនត្រូវបានបង្កើតក្នុងតំបន់ស្វាយប៉ាក។ ផលិតផលគ្រប់ប្រភេទមានសម្រាប់ភ្ញៀវ កំពុងតែកើនឡើងនូវកម្រិតអសន្តិសុខ។

ជាសេចក្តីសន្និដ្ឋានពុំមានការសង្ស័យណាមួយដែលថា ការបិទតំបន់ស្វាយប៉ាកត្រូវតែទទួលបានការស្វាគមន៍ គ្មានបញ្ហាអ្វីដែលមានផលវិបាកលើផលប្រយោជន៍ដោយប្រយោលរបស់ប្រជាជនក្នុងមូលដ្ឋាន ដែលបានមកពីអំពើពេស្យាចារនោះទេ ប៉ុន្តែយើងត្រូវតែយល់ថា វិធីពេស្យាចារសព្វថ្ងៃមានការទាក់ ទិនជាមួយសកម្មភាពសេដ្ឋកិច្ចដ៏ច្រើន និងទម្ងន់សេដ្ឋកិច្ចដែលវាតំណាង។ កង្វះខាតនៃប្រសិទ្ធភាពគោលនយោបាយ និងអន្តរាគមន៍ប្រឆាំងនឹងការកេងប្រវ័ញ្ចពាណិជ្ជកម្មផ្លូវភេទលើកុមារ និងស្ត្រីត្រូវបានពាក់ព័ន្ធយ៉ាងច្បាស់ទៅនឹងទម្ងន់ ដែលពេស្យាចារបានធ្វើក្នុងសង្គមខ្មែរ។

## ៧.៤ ការប៉ាន់ប្រមាណនៃឥទ្ធិពលលើការឆ្លក់ចូលស្ដីពីសកម្មភាពសុខមាលភាពសង្គម និងសហគមន៍ដោយអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ

ដោយគ្មានការរិះគន់ចំពោះការបិទតំបន់ស្វាយប៉ាក យើងអាចអង្កេតឃើញនូវការផ្លាស់ប្តូរនៃសកម្មភាពពាណិជ្ជកម្មផ្លូវភេទទៅកាន់កន្លែងផ្សេងៗ។ ក្មេងស្រី និងកុមាររកស៊ីផ្លូវភេទពីមុនៗត្រូវការការយកចិត្តទុកដាក់ ហើយជួនកាលវាមិនអាចត្រូវបានធានា ឬតម្រូវតាមពួកគេនោះទេ (ជនអន្តោប្រវេសន៍, ជនបរទេស)។ ទំនាក់ទំនងត្រូវការកសាងឡើងវិញរវាងអង្គការក្រៅរដ្ឋាភិបាល និងម្ចាស់បនទាក់ទងនឹងផលវិបាកផ្នែកសុខភាពលើប្រជាជនរកស៊ីផ្លូវភេទ។ ជាឧទាហរណ៍ អង្គការខេមរា : ការបិទផ្ទះបនជាធម្មតានាំមកនូវលទ្ធផលនៃការផ្លាស់ប្តូរក្មេងស្រីរកស៊ីផ្លូវភេទទៅផ្ទះបនថ្មីក្នុងតំបន់ផ្សេងៗ អង្គការខេមរាប្រឈមមុខជាមួយភាពលំបាកខ្លះក្នុងការអនុវត្តន៍តាមពួកគេ។ អំឡុងពេលធ្វើសំភាសន៍នានា ក្មេងស្រីរកស៊ីផ្លូវភេទបានអះអាងថា ពួកគេឥតមានលទ្ធភាពទៅកាន់គ្លីនិកជម្ងឺកាមរោគទេ។ ពីព្រោះក្នុងកន្លែងការងារថ្មីរបស់ពួកគេ ពួកគេមិនបានដឹងកន្លែងដែលគ្លីនិកផ្តល់សេវាកម្មដោយអង្គការ និងហេតុផលផ្សេងទៀតពីព្រោះជនជាតិយួនមិនអាចនិយាយភាសាខ្មែរ។ ក្មេងស្រីរកស៊ីផ្លូវភេទជាច្រើនទៅឱសថស្ថានដើម្បីព្យាបាលជម្ងឺឆ្លងដោយខ្លួនឯង។

ចំពោះអង្គការ MEC សកម្មភាពត្រូវបានកាត់បន្ថយពីបួន (ការព្យាបាលជំងឺកាមរោគ ពន្លូតកូន ផែនការគ្រួសារ ព្យាបាលទូទៅ) មកនៅត្រឹមពីរប៉ុណ្ណោះឥឡូវនេះ (ការព្យាបាលជំងឺកាមរោគ និងពិសោធន៍)។ ក្មេងស្រី

រកស៊ីផ្លូវភេទមួយចំនួននៅតែកំពុងធ្វើការនៅក្នុងតំបន់ស្វាយប៉ាកនៅឡើយ ប៉ុន្តែពួកគេនឹងមិនទៅគ្លីនិកទេ ដោយភ័យខ្លាចនគរបាល។

លើសពីនេះទៅទៀត ការសង្ស័យដ៏ខ្លាំងចំពោះការព្យាបាលរបស់អង្គការក្រៅរដ្ឋាភិបាលកំពុងក្លាយជាបញ្ហាពិតជាក់ស្តែងដើម្បីព្យាបាលក្មេងស្រីរកស៊ីផ្លូវភេទ។ ទំនាក់ទំនងជាមួយកុមាររកស៊ីផ្លូវភេទ និងកុមារដែលត្រូវគេកេងប្រវ័ញ្ច ជាធម្មតាមិនអាចធ្វើទៅបានទេ ហើយក៏មិនត្រូវបានការអនុញ្ញាតដែរ ដែលអាចចាត់ទុកថា គ្មានជំនួយណាមួយសម្រាប់កុមារដែលស្ថិតក្នុងគ្រោះថ្នាក់នោះទេ។

## ៨. ការសន្និដ្ឋាន និងស្ថានភាពនៃតំបន់ស្វាយប៉ាកក្នុង ខែមករា ឆ្នាំ ២០០៥

ប្រសិនបើ យើងស្វាគមន៍យ៉ាងខ្លាំងក្លានូវការបិទតំបន់ស្វាយប៉ាកកាលពី ខែមករា ឆ្នាំ ២០០៥ មានភស្តុតាងជាដុំកំភួនដែលបង្ហាញពីសកម្មភាពពាណិជ្ជកម្ម ផ្លូវភេទក្នុងតំបន់ស្វាយប៉ាក បានចេញជាលទ្ធផលក្នុងកម្រិតមួយជាការរីកសាយភាយនៃសកម្មភាពបែបនេះនៅកន្លែងផ្សេងៗទៀត។ ប្រជាជនរកស៊ីផ្លូវភេទពីមុននៃតំបន់ស្វាយប៉ាកភាគច្រើនត្រូវបានបែងចែកទៅទិសដៅពីរ : ភ្នំពេញ និងសៀមរាប។ ផ្ទុយទៅនឹងទីក្រុងភ្នំពេញ ក្មេងស្រីរកស៊ីផ្លូវភេទភាគច្រើនត្រូវបានគេដាក់ជាក្រុមក្នុងតំបន់មួយនាខេត្តសៀមរាប។ លើសពីនេះទៅទៀតនេះគឺ ជាបណ្តាញឬសហគមន៍ពេញលេញមួយដែលឈានទៅរកការប្រកបជំនួញស្រដៀងៗគ្នាមួយរួមមានអនីតិជនដែរ។ ក្នុងទីក្រុងភ្នំពេញប្រជាជនរកស៊ីផ្លូវភេទត្រូវបានបំបែកក្នុងចំណោមតំបន់ពេស្យាចារ ដែលមានស្រាប់ជាមួយនឹងផ្នែកដ៏សំខាន់នៃកុមារនៅម្តុំវត្តភ្នំ។

វាទំនងថា ផ្ទះបនមានការផ្លាស់ប្តូរដោយមានកុមារ និងស្ត្រីក្មេងៗ។ កត្តានេះអាចតម្រូវអោយមានចរន្តបំណុលបន្ថែមចំពោះកុមារ និងក្មេងស្រីរកស៊ីផ្លូវភេទដែលបានខ្ចីបុលគេ ហើយវាធ្វើឱ្យយ៉ាប់យ៉ឺនឡើងនៃសិទ្ធិជាមនុស្សរបស់ពួកគេ។ តាមពិត យើងបានសង្កេតឃើញថា តំបន់ថ្មីមានតួនាទីយ៉ាងសំខាន់លើកម្រិតជីវភាពរស់នៅរបស់ប្រជាជនដែលរកស៊ីផ្លូវភេទ។ លើចំណុចនេះដែរក្រុងសៀមរាបផ្តល់ឱ្យទាំងម្ចាស់បន និងក្មេងស្រីរកស៊ីផ្លូវភេទនូវកន្លែងដែលមានសុវត្ថិភាព និងអាចរកកម្រៃបានច្រើនជាងតំបន់ស្វាយប៉ាក។ ទោះបីយ៉ាងណាក៏ដោយភ្ញៀវរួមភេទនៅទីនោះមានចំនួនតិចជាង។

ដោយការមានការពាក់ព័ន្ធទៅនឹងអាយុរបស់ប្រជាជនរកស៊ីផ្លូវភេទ ផលវិបាកនៃការបិទតំបន់ស្វាយប៉ាកជាក់ស្តែងមានភាពខុសប្លែកគ្នា។ ជាការពិតប្រសិន បើយើងកត់ចំណាំភាពប្រសើរឡើងមួយចំនួនចំពោះស្ត្រីរកស៊ីផ្លូវភេទដែលមានចំណាស់បំផុត កម្រិតជីវភាពរស់នៅថ្មីនៃកុមារដែលត្រូវបានគេជួញដូរ និងកេងប្រវ័ញ្ចលើផ្លូវភេទមានលក្ខណៈអាក្រក់ជាងពីមុន ហើយការកេងប្រវ័ញ្ចពាណិជ្ជកម្ម ផ្លូវភេទរបស់គេស្ថិតនៅក្រោមភាពលាក់កំបាំង

ទាំងស្រុង។ ការស៊ើបអង្កេតរយៈពេលយូរដើម្បីចាប់មេបន និងរៀបចំការធ្វើសមាហរណកម្មកុមារ ឥឡូវនេះត្រូវបានផ្តល់អនុសាសន៍យ៉ាងពេញទំហឹង។ ដោយយល់ឃើញថា ការបិទតំបន់ពេស្យាចា ដោយពុំមានការចាប់ខ្លួនមនុស្សសំខាន់ៗកំពុងមានផលវិបាកជាអវិជ្ជមានលើកម្មវិធីរបស់អង្គការក្រៅរដ្ឋាភិបាល លើកេរ្តិ៍ឈ្មោះអង្គការក្រៅរដ្ឋាភិបាល និងលើកម្រិតជីវភាពរស់នៅរបស់ប្រជាជនដែលត្រូវបានជួញដូរ។ ម្យ៉ាងវិញទៀតយើងយល់ថា ការបិទតំបន់ស្វាយប៉ាកអាចល្អសម្រាប់កេរ្តិ៍ឈ្មោះរបស់ប្រទេសនេះ។

លើសពីនេះទៅទៀត វិសាលភាពនៃសេវាពាណិជ្ជកម្មផ្លូវភេទទៅកាន់តំបន់ "ថ្មី" អាចនាំមកនូវលទ្ធផលជាការប៉ះទង្គិចសហគមន៍មូលដ្ឋានបានផ្តល់នូវការរីករាលដាលនៃការឆ្លងជម្ងឺកាមរោគ ដោយសារតែខ្វះនូវព័ត៌មានដែលពាក់ព័ន្ធ និងអតុល្យភាពក្នុងសកម្មភាពសេដ្ឋកិច្ចក្នុងមូលដ្ឋាន។ បន្ថែមពីលើនេះទៀត ក្នុងខេត្តសៀមរាបការមកដល់របស់ជនជាតិយួន ១០០នាក់ បានប៉ះពាល់ដល់មូលដ្ឋាននោះយ៉ាងលើសលប់ក៏ដូចជាដល់ខ្លួនគេផងដែរ។ ឥឡូវនេះស្ត្រីរកស៊ីផ្លូវភេទដែលបានជួបក្នុងក្រុងសៀមរាបបានពន្យល់ប្រាប់យើងថា គ្លីនិក ឬអង្គការក្រៅរដ្ឋាភិបាលផ្សេងៗដែលនៅក្បែរតំបន់រស់នៅរបស់ពួកគេមិនបានជួលអ្នកនិយាយភាសាយួនឱ្យធ្វើការទេ ការនេះវាធ្វើឱ្យលំបាកក្នុងការផ្តល់សកម្មភាពថែទាំសុខភាពឱ្យមានប្រសិទ្ធភាព ជាពិសេសសម្រាប់ប្រជាជនដែលងាយរងគ្រោះ។

ឥឡូវនេះមានជនបរទេសតិចតួចប៉ុណ្ណោះដែលកំពុងទៅតំបន់ស្វាយប៉ាក តាមពិតទៅដោយសារតែពួកគេមិនបានដឹងអំពីកាបិទនេះ ប៉ុន្តែមេបននៅតែដឹកនាំពួកគេទៅកាន់កន្លែងពេស្យាចារដទៃទៀត ឬទៅកាន់នណាម្នាក់ដែលពួកគេត្រូវការ។ ជាក់ស្តែង ជនបរទេសខ្លះបានបង្កើតនូវការទំនាក់ទំនងយូរអង្វែងជាមួយ និងម្ចាស់បន។ ពួកគេទៅលេងស្វាយប៉ាកជាប្រចាំ ឬក៏បាននិងកំពុងធ្លាក់ក្នុងអន្លង់ស្នេហ៍ជាមួយស្ត្រីរកស៊ីផ្លូវភេទណាម្នាក់។

អំពើពេស្យាចារនៅតែកើតមានទូទាំងប្រទេសកម្ពុជា ក៏ដូចជាក្នុងតំបន់ស្វាយប៉ាកផងដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ពេស្យាចារក្នុងតំបន់ស្វាយប៉ាកបច្ចុប្បន្នមានទិសដៅសម្រាប់ភ្ញៀវក្នុងស្រុកសុទ្ធសាធ។ ផ្ទះបនខ្លះបានក្លាយជាហាងកាហ្វេជាផ្លូវការ។ សកម្មភាពសេដ្ឋកិច្ច ឬជំនួញថ្មីទាំងនេះ គឺជាផលវិបាកនៃវិនិយោគទុនថ្មីដោយមានជំពាក់បំណុលជាច្រើនគ្រួសារ ដែលពីមុនមកទទួលផលប្រយោជន៍ពីសកម្មភាពផ្ទុយច្បាប់នេះ។ គ្រួសារទាំងអស់កាត់បន្ថយនូវការចំណាយប្រចាំថ្ងៃរបស់គេ ហើយព្យាយាមប្រុងប្រយ័ត្នបន្ថែម។ ភូមិនោះកំពុងព្យាយាមសង្គ្រោះពីការបង្ក្រាបនេះ ប៉ុន្តែលទ្ធភាពដែលអាចធ្វើបានកំពុងតែរីកដុះដាលពាសពេញតំបន់នេះ *"សាលាក្រុងភ្នំពេញនឹងផ្តោះទៅមុខជាមួយនឹងផែនការរបស់ខ្លួន ដើម្បីប្រែក្លាយតំបន់ពេស្យាចារដែលគេដឹងឮគ្រប់គ្នាមួយនេះទៅជាមជ្ឈមណ្ឌលពាណិជ្ជកម្មកម្រិតខ្ពស់ដោយការលើកតម្កើងកម្រិតមូលដ្ឋាននៃតំបន់នោះទាំងមូល"*[៩]។

[៩] ឌឹ ខេមបូឌៀ ដេលី ថ្ងៃអង្គារ ទី ១១ ខែមករា ឆ្នាំ ២០០៥ ទំព័រទី ១២

ប្រហែលដើមខែកុម្ភៈ ខ្សែភាពយន្តអាមេរិកមួយបាននឹងកំពុងបញ្ចាំងក្នុងតំបន់ស្វាយប៉ាក ដោយនិយាយអំពីរឿងរ៉ាវនៃក្មេងស្រីរកស៊ីផ្លូវភេទ និងភ្ញៀវជនជាតិអាមេរិកាំងដែលកំពុងធ្លាក់ក្នុងអន្លង់ស្នេហ៍ជាមួយនាងម្នាក់។ ខ្សែភាពយន្តនេះបាននាំមកនូវប្រាក់ចំណូលខ្លះជូនអ្នកស្រុកដែលបានចំណាយ ៧ដុល្លា ក្នុងមួយថ្ងៃ ហើយវាក៏ប្រាកដផងដែរថា ជាអំណោយសម្រាប់នគរបាល និងកងកម្លាំងអាវុធហត្ថ។ កាលណាខ្សែភាពយន្តនេះបញ្ចាំងចប់ស្វាយប៉ាកនឹងបញ្ឈប់នូវការបញ្ចាំងនេះ។ ប៉ុន្តែប្រសិនបើគោលបំណងសំខាន់នៃការបិទនេះ គឺដើម្បីជៀសវាងទាំងស្រុងនូវការផ្សព្វផ្សាយអាក្រក់ចំពោះប្រទេសកម្ពុជានោះ។ ជាអកុសល ខ្សែភាពយន្តប្រភេទនេះនឹងបន្ថែមនូវមុខមាត់ប្រទេសកម្ពុជាថា ជាទីកន្លែងផ្លូវភេទមួយ។

## ៩. អនុសាសន៍

បញ្ហាពេស្យាចារក្នុងតំបន់អាស៊ី មានលក្ខណៈស្មុគស្មាញច្រើនជាងការពិពណ៌នាធម្មតា។ ជាក់ស្តែងនៅក្នុងប្រទេសជាច្រើនតម្លៃវប្បធម៌ស្ថិតនៅយូរអង្វែង ដែលជួយចិញ្ចឹមដល់ឧស្សាហកម្មនៃការជួញដូរ ជាពិសេសឧស្សាហកម្មផ្លូវភេទលើកុមារ។ ភាពក្រីក្រដែលចេះតែកើនឡើង និងអសន្តិសុខម្ហូបអាហារបានបន្ថែមនូវភាពងាយរងគ្រោះដល់កុមារក្នុងការជួញដូរ។ ប៉ុន្តែប្រភពសំខាន់នៃការជួញដូរ គឺជាអត្ថិភាពនៃតម្រូវការនេះឯង។ វិស័យទេសចរណ៍ និងការកើនឡើងនៃតម្រូវការក្មេងស្រីដើរតួនាទីយ៉ាងសំខាន់ក្នុងការកេងប្រវ័ញ្ចផ្លូវភេទ និងពាណិជ្ជកម្មផ្លូវភេទលើកុមារ។ Chutikul (១៩៩៩)[១០] បានអះអាងថា ការសិក្សាជាច្រើនបានរាយការណ៍រួចមកហើយថា ការរីករាលដាលនៃជម្ងឺហ៊ីវ/អេដស៍បានបង្កើននូវតម្រូវការនារីវ័យកាន់តែក្មេងក្នុងឧស្សាហកម្មផ្លូវភេទ។ តម្លៃចំណាយលើព្រហ្មចារីរបស់ក្មេងស្រីអាស្រ័យលើកត្តាវប្បធម៌ទាំងនេះ ដែលបានចែករំលែករវាងកត្តាបុគ្គល និងសង្គម។ ដូច្នេះជាដំបូងបំផុតកិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងត្រូវការឱ្យការទទួលស្គាល់ដើម្បីប្រយុទ្ធប្រឆាំងនឹងជំនឿ និងតម្រូវការកុមាររបស់អ្នកទេសចរ។

ដូចបានជម្រាបជូនខាងលើ ការស៊ើបអង្កេតដ៏យូរអង្វែង ដើម្បីចាប់ខ្លួនមេបនក៏ត្រូវបានផ្តល់អនុសាសន៍យ៉ាងខ្លាំងផងដែរ។ អំណះអំណាងដូចជា "កុមារដែលត្រូវបានសង្គ្រោះទាំងអស់នឹងត្រូវបានជំនួសដោយកុមារផ្សេងទៀត" ជាអកុសលវាជារឿងពិត ហើយកិច្ចប្រឹងប្រែងសកម្មរួមគ្នាត្រូវតែបានអនុវត្តដើម្បីកម្ទេចចោលនូវបណ្តាញជួញដូរមនុស្ស និងបុគ្គលដែលត្រូវមានខ្នងបង្អែកការពារនៅពីក្រោយរបស់ពួកគេ។ វាចាំបាច់ណាស់ដើម្បីបង្កើនចំនួននៃការចាប់ខ្លួន និងកាត់ទោសអ្នកទាំងឡាយណាដែលបានពាក់ព័ន្ធនឹងការជួញដូរៈ ដូចជាអ្នកជ្រើសរើសអ្នកដឹកជញ្ជូនអ្នកការពារជន ដែលរក្សាទុកមនុស្សក្នុងស្ថានភាពដូចជា ទេសករ ឬជនប្រព្រឹត្តបទឧក្រិដ្ឋដទៃទៀត។ ការនេះអាចសម្រេចបានតាមរយៈការធ្វើអោយប្រសើរឡើងនូវសមត្ថភាពរបស់ភ្នាក់ងារអនុវត្តច្បាប់ និងធានាថា

---

១០ Chutikul Saisuree, ការកេងប្រវ័ញ្ចពាណិជ្ជកម្មផ្លូវភេទ ការជួញដូរឆ្លងដែន ការរំលោភផ្លូវភេទ និង អំពើហិង្សាលើកុមារ និងស្ត្រី , ដោយអង្គការ ESCAP ខែកក្កដា ឆ្នាំ ១៩៩៩។

មន្ត្រីអនុវត្តន៍ច្បាប់ប្រតិបត្តិកាតព្វកិច្ចរបស់ខ្លួនដោយស្របច្បាប់។ វាក៏ចាំបាច់ផងដែរ ក្នុងការបញ្ចុះបញ្ចូលអ្នកបង្កើតគោលនយោបាយដើម្បីផ្តល់នូវការការពារស្របច្បាប់ ចំពោះជនរងគ្រោះពីការជួញដូរ ដោយមិនប្រកាន់អាយុជីវិតរបស់ពួកគេ។

បន្ថែមពីលើនេះទៀត ដំណើរការ និងការផ្គត់ផ្គង់ទាំងផ្នែកសង្គម និងចិត្តសាស្ត្រត្រូវការការអនុវត្តន៍ និងរៀបចំផែនការយ៉ាងប្រុងប្រយ័ត្នដោយអង្គការក្រៅរដ្ឋាភិបាល។ រហូតដល់ឥឡូវនេះ សកម្មភាពទាំងនេះជាធម្មតាមិនទាន់ត្រូវបានដាក់បញ្ចូលក្នុងអន្តរាគមន៍សង្គ្រោះរបស់អង្គការក្រៅរដ្ឋាភិបាលជាច្រើននៅឡើយទេ លើកលែងតែអង្គការទាំងឡាយណា ដែលកំពុងអនុវត្តសកម្មភាពទាំងពីរនេះ។ កិច្ចសហប្រតិបត្តិការរឹងមាំ និងយូរអង្វែងរវាងអង្គការក្រៅរដ្ឋាភិបាលជាមួយរដ្ឋាភិបាលតាមរយៈអង្គភាពនគរបាលរួមមានផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសត្រូវតែបានរៀបចំផងដែរ ដើម្បីគ្រប់ដណ្តប់គ្រប់ជំហានពីការសង្គ្រោះ រហូតដល់ការធ្វើសមាហរណកម្មនៅក្នុងសង្គម។ ជំហានទាំងអស់នៅក្នុងដំណើរការនេះមានការចំណាយ និងកម្មវិធីសមាហរណកម្ម ដែលត្រូវតែមានផែនការ និងការរៀបចំមិនត្រឹមតែផ្នែកបច្ចេកទេសប៉ុណ្ណោះទេ តែថែមទាំងផ្នែកហិរញ្ញវត្ថុផងដែរ។

ដើម្បីធ្វើការសន្និដ្ឋាន ការជួញដូរមនុស្សមិនអាចត្រូវបានដោះស្រាយ ដោយពុំមានដំណើការល្អពីជំនួយខាងក្រៅរហូតដល់ខាងក្នុង។ ការចាប់ផ្តើមតាម រយៈការយល់ដឹងជាទូរទៅអំពីការគ្រោះថ្នាក់នៃការជួញដូរនៅឯកម្រិតសហគមន៍ និងការអភិវឌ្ឍន៍សហគមន៍នេះបានពឹងផ្អែកលើកម្មវិធីដែលផ្តល់នូវជម្រើសជីវភាពរស់នៅដើម្បីរក្សាឱ្យប្រជាជនទាំងនោះរស់នៅក្នុងភូមិ/ប្រទេស។ ប៉ុន្តែបើពុំមានកិច្ចសហការទំនាក់ទំនង និងការចែករំលែកព័តិមានរបស់ភ្នាក់ងារពាក់ព័ន្ធទាំងអស់ អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ជំនួយ និងរដ្ឋាភិបាលទេនោះក៏គ្មានលទ្ធផលដែលមានតម្លៃទាំងអស់នេះនឹងកើតមានក្នុងរយៈពេលដប់ឆ្នាំបន្ទាប់ទៀតដែរ។ ជាពិសេស វាហាក់បីដូចជាឥតប្រយោជន៍ក្នុងការបន្តការបង្កើតច្បាប់ និងគោលការណ៍ថ្មីនៅពេលដែលឧបករណ៍ទាំងនេះមានរួចហើយ ប៉ុន្តែជាធម្មតាគ្រាន់តែមិនត្រូវបានអនុវត្តន៍ប៉ុណ្ណោះ។ ការនេះមានន័យថា ការទទួលយកនូវគោលនយោបាយ កម្មវិធី និងវិធានការទាំងអស់ដើម្បីឱ្យមានការអភិវឌ្ឍន៍ និងឱ្យរដ្ឋាភិបាលដើរតួនាទីដោយខ្លួនឯងក្នុងនាមជាអ្នកសហការ អ្នកសម្របសម្រួល និងអ្នកប្រតិបត្តិការ។

## ឧបសម្ព័ន្ធទី ១

**<u>សេចក្តីបន្ថែម</u> : គ្រប់ព័ត៌មានទាំងអស់នៅខាងក្រោម និងព័ត៌មានលម្អិតបន្ថែមទៀតត្រូវបានបញ្ជូនទៅឱ្យកម្មវិធីនាយកដ្ឋានប្រឆាំងការជួញដូរ ហើយនឹងនៅតែរក្សាការសម្ងាត់រហូតដល់ការបញ្ចប់នៃការស៊ើបអង្កេតរបស់នគរបាល។**

**ឯកសារសំភាសន៍ និងការស៊ើបអង្កេត (ខែមករា ឆ្នាំ ២០០៥):**

១. ក្នុងតំបន់វត្តភ្នំ យើងបានរកឃើញកន្លែងមេបនម្នាក់ (តែមួយប៉ុណ្ណោះដែលបានឃុំកុមារ ដែលត្រូវបានកេងប្រវ័ញ្ចពីមុនក្នុងតំបន់ស្វាយប៉ាក : ផ្ទះបនលេខ ៩ និងលេខ ១៦) បានបោះទីតាំងសារជាថ្មី។ យើងបានឃើញកុមាររកស៊ីផ្លូវភេទ ពីរនាក់ ដែលរកស៊ីនៅតំបន់ស្វាយប៉ាកពីមុន។ យើងមិនបានដឹងថា តើពួកគេកំពុងរង់ចាំភ្ញៀវ ឬក៏កំពុងលំហែរកាយលេងនោះទេ។ យើងបានឃើញអ្នកម៉ូតូឌុបម្នាក់ដែលពីមុនធ្វើការផ្គាច់មុខអោយម្ចាស់ផ្ទះបននេះក្នុងតំបន់ស្វាយប៉ាក (ឌុបកុមាររកស៊ីផ្លូវភេទទៅសណ្ឋាគារដើម្បីជួបភ្ញៀវ ។ល។)

២. ពីមុននៅក្នុងតំបន់ស្វាយប៉ាក មេបននោះមានអាគារពីរ (លេខ ៩ និង លេខ ១៦) ហើយមានកុមាររកស៊ីផ្លូវភេទ ៤០នាក់។ ក្មេងស្រីទាំងនោះស្ថិតនៅក្នុងស្ថានភាពគួរឱ្យរន្ធត់ - ពួកគេត្រូវបានឃុំឃាំងទុកក្នុងក្រុមដាច់ដោយឡែក១ក្នុងផ្ទះបននីមួយ១ពួកគេត្រូវបានគេវាយដំ ប្រសិនបើ ពួកគេមិនយកចិត្តទៅកែ ពួកគេមិនបានប្រើប្រាស់ស្រោមអនាម័យ ឬមិនបានទទួលព័ត៌មាន ដែលពាក់ព័ន្ធនឹងជម្ងឺកាមរោគរាប់បញ្ចូលទាំងជម្ងឺហ៊ីវ ហើយមេបនមិនបានអនុញ្ញាតឱ្យពួកគេទៅរកគ្លីនិកសុខភាពទេ។ ពីមុនមេបនបានដោះលែងពួកគេដែលមានអាយុ ១៤ឆ្នាំ ទៅ ១៥ឆ្នាំ។ ក្រោយមកពួកគេមានលទ្ធភាពទៅកាន់គ្លីនិកហើយផ្តល់នូវព័ត៌មានមួយចំនួន។ នារីរកស៊ីផ្លូវភេទដែលរត់គេចខ្លួនរួចមានផ្ទុកជម្ងឺឆ្លងយ៉ាងធ្ងន់ធ្ងរ។

៣. យើងបានធ្វើសំភាសន៍បុរសម្នាក់ ដែលរស់នៅក្បែរផ្ទះថ្មីមួយក្នុងចំណោមផ្ទះថ្មីទាំងអស់សម្រាប់កុមារ និងក្មេងស្រីរកស៊ីផ្លូវភេទ។ គាត់គឺជាប្រភពព័ត៌មានដែលគួរឱ្យទុកចិត្តលើស្ថានភាពក្នុងផ្ទះបន។ គាត់បានប្រាប់យើងថា មេបននេះបានទិញផ្ទះថ្មីពីរ។ ឥឡូវនេះនាងមានក្មេងស្រីរកស៊ីផ្លូវភេទជាអនីតិជនប្រហែលជា ១២ ទៅ ២០នាក់។ នគរបាលដែលការពារមេបននោះបានមកប្រមូលលុយពីនាងរៀងរាល់ថ្ងៃក្នុងវត្តភ្នំ។ អ្នកផ្តល់ព័ត៌មាននេះស្រដៀងគ្នាជាមួយចលនាអន្តរជាតិនៃនារីរកស៊ីផ្លូវភេទ ដែលឆ្លងកាត់ប្រទេសកម្ពុជាទៅកាន់ប្រទេសដទៃទៀតរួមមានប្រទេសថៃ ម៉ាឡេស៊ី សឹង្ហបុរី ទីក្រុងម៉ាកាវ និងហុងកុង។

ពួកគេកាន់លិខិតឆ្លងដែនយួន ហើយមានលទ្ធភាពទទួលបានទិដ្ឋាការទេសចរណ៍ស្នាក់នៅរយៈពេលខ្លីទៅកាន់ទិសដៅរបស់គេ។

៤. នៅថ្ងៃទី ១១ ខែ មករា យើងបានទៅដល់ទួលគោក ហើយបានឃើញថា មេបនមានក្មេងស្រីរកស៊ីផ្លូវភេទជាង ១៥នាក់ មកពីផ្ទះបនលេខ ១២ ក្នុងតំបន់ស្វាយប៉ាកបានផ្លាស់ប្តូរទៅកាន់ទួលគោក។ យើងបានពិភាក្សាជាមួយមេបន និងក្មេងស្រីរកស៊ីផ្លូវភេទមួយចំនួន។ ពួកគេជួលផ្ទះថ្មីដោយមានតម្លៃ ៣០០ ដុល្លាក្នុង១ខែ។ ពួកគេត្រូវបង់ថ្លៃទឹកភ្លើងផងដែរ (ចំណាយសរុបច្រើនជាងនៅក្នុងតំបន់ស្វាយប៉ាក)។ នគរបាលពីទួលគោកមកប្រមូលលុយជារៀងរាល់ថ្ងៃជួនកាល ១០០០០រៀល ជួនកាល ៥០០០រៀល។ វាមានសុវត្ថិភាពក្នុងតំបន់ទួលគោកពីព្រោះគ្មានការឆ្មក់ចូល។ ផ្ទះបនបិទពេលថ្ងៃដោយបើកចាប់ពីម៉ោង ៥ល្ងាចរហូតដល់ម៉ោង៣ ឬម៉ោង ៤ទៀបភ្លឺ។ ភាគច្រើនភ្ញៀវគឺជាប្រជាជនក្នុងស្រុក (ពោលគឺមិនមែនជាជនបរទេស)។ ក្មេងស្រីរកស៊ីផ្លូវភេទមិនមានលទ្ធភាពទៅកាន់គ្លីនិចដូចស្ថានភាពនៅស្វាយប៉ាកដែរ។ ក្មេងស្រីរកស៊ីផ្លូវភេទទិញថ្នាំពីឱសថស្ថានក្នុងតំបន់។

៥. យើងបានធ្វើសំភាសន៍ជាមួយស្រីម៉ាស្សាម្នាក់។ នាងបានផ្លាស់ប្តូរទៅមាត់ទន្លេរយៈពេលបីខែកន្លងមកនេះ ពោលគឺតាំងពីនគរបាលបិទតំបន់ស្វាយប៉ាក។ នាងជួលបន្ទប់មួយដោយមានតម្លៃ ១៥០ដុល្លា ក្នុងមួយខែ ហើយត្រូវចំណាយទឹកភ្លើងក្រៅបន្ថែមទៀត។ ពីមុននាងជួលបន្ទប់ស្រដៀងគ្នានេះដែរនៅតំបន់ស្វាយប៉ាក ដែលមានតម្លៃត្រឹមតែ ៣០ដុល្លា ក្នុង ១ខែ បូកជាមួយទឹកភ្លើង ៥ដុល្លា ក្នុង ១ខែ។ នាងមិនអាចមានលទ្ធភាពបង់នូវការជួលនេះទេ ឥឡូវនាងធ្លាក់ខ្លួនឈឺខ្លាំងណាស់។ សប្តាហ៍មុននគរបាលបានឆ្មក់ចូលនៅកន្លែងរបស់នាង ប៉ុន្តែនាងបានរត់គេចខ្លួនរួច។ នគរបាលបានរឹបអូសយករបស់របរក្នុងទីបរិវេននេះទាំងអស់។ នគរបាលក៏បានចាប់មេបនផងដែរ ដោយទារលុយ ៣០ដុល្លា ពីគាត់។ នៅពេលដែលគាត់អត់មានលុយគាត់ត្រូវបានបញ្ជូនទៅទីស្នាក់ការនគរបាល។ ចុងក្រោយនគរបាលបានដោះលែងគាត់ បន្ទាប់ពីរឹបអូសយកស្បែកជើងរបស់គាត់។ អ្នករកស៊ីម៉ាស្សាបានរាយការណ៍ថា ឥឡូវនេះនាងមានជីវិតលំបាកណាស់ នាងត្រូវការស្រោមអនាម័យ និងថ្នាំពេទ្យពីអង្គការក្រៅរដ្ឋាភិបាល ពីព្រោះនាងមិនមានលទ្ធភាពទិញបានទេ។

៦. យើងបានធ្វើសំភាសន៍ក្មេងស្រីរកស៊ីផ្លូវភេទ ៧នាក់ នៅរង្គសាលម៉ាធីនី ក្នុងក្រុងភ្នំពេញ។ អតីតជាក្មេងស្រីរកស៊ីផ្លូវភេទមកពីផ្ទះបនលេខ ១៤ កំពុងរកស៊ីដោយគ្មានកិច្ចសន្យាក្នុងរង្គសាលនេះ។ ឥឡូវនេះពួកគេបានរស់នៅដោយឯករាជ្យពីផ្ទះបន ដោយជួលបន្ទប់ស្នាក់នៅ (ជាទូរទៅមានគ្នា ២នាក់ ចូលលុយគ្នាបង់ថ្លៃបន្ទប់) ក្នុងទីក្រុងភ្នំពេញ។ ពួកគេអាចរកលុយបានច្រើនមានសេរីភាពជាង ហើយមិនសូវមានការ

ភ័យខ្លាចនគរបាលដូចមុនទេ។ ក្មេងស្រីរកស៊ីផ្លូវភេទមានកាតព្វកិច្ចបង់កម្រៃជើងសារ ១០ភាគរយ ទៅឱ្យម៉ែយ៉ៃមនៅពេលដែលពួកគេបានទទួលភ្ញៀវម្នាក់។ នារីរកស៊ីផ្លូវភេទទាំងនេះបាននិយាយថា ភ្ញៀវក្នុងរង្គសាលនេះប្រើប្រាស់ស្រោមអនាម័យ។

៧. ក្នុងខេត្តសៀមរាប យើងបានទៅដល់ផ្ទះបនបីដំបូង។ ផ្ទះបនទីមួយ (ពីមុនជាផ្ទះបនលេខ ២២ ក្នុងតំបន់ស្វាយប៉ាក) មានក្មេងស្រី ១៥នាក់ កំពុងធ្វើការ (មានអ្នកខ្លះមកពីផ្ទះបនស្វាយប៉ាកលេខ ៨ និង លេខ ២០)។ ក្មេងស្រីរកស៊ីផ្លូវភេទទាំងនេះបាននិយាយថាស្ថានភាពរស់នៅ និងស្ថានភាពការងារមានភាពប្រសើរជាងតំបន់ស្វាយប៉ាក ពីព្រោះមិនមានការរំខានរបស់នគរបាល ឬការចាប់ខ្លួនទេ។ ភ្ញៀវបានបង់ថ្លៃសេវាច្រើនផងដែរ : ក្នុងស្វាយប៉ាកបុរសក្នុងស្រុកបង់ថ្លៃ ១០០០០រៀល ក្នុងខេត្តសៀមរាបមានតម្លៃ ៣ដុល្លា ស្មើនឹង ១២០០០រៀល នៅខណៈពេលដែលជនបរទេសបង់តម្លៃ ៥ដុល្លា នៅស្វាយប៉ាក ផ្ទុយមកវិញ ១០ដុល្លា នៅសៀមរាប។ ក្មេងស្រីរកស៊ីផ្លូវភេទមានការសប្បាយចិត្ត ដោយទទួលបានសេរីភាពច្រើនក្នុងការដើរលំហែរកាយដូចជា ការមើលប្រាសាទអង្គរវត្តជាដើម។ល។ មេបនបាននិយាយថា តម្លៃឈ្នួលផ្ទះ និងទឹកភ្លើងមានលក្ខណៈថ្លៃក្នុងខេត្តសៀមរាបជាងតំបន់ស្វាយប៉ាក អញ្ចឹងហើយទើបបានជាមានតម្លៃខ្ពស់សម្រាប់សេវារួមភេទ ដោយសារតែការចំណាយបន្ថែមទាំងនេះមានការថ្លៃខ្ពស់។

៨. ក្នុងខេត្តសៀមរាប មានក្មេងស្រីម្នាក់មានការត្អូញត្អែរអំពីប្រព័ន្ធពិនិត្យសុខភាព : មិនមានបុគ្គលិកនិយាយភាសាយួននៅក្នុងគ្លីនិក ដូច្នេះហើយមានភាពបរាជ័យដ៏ធំក្នុងការទំនាក់ទំនងគ្នា។ នាងក៏មិនសប្បាយចិត្តផងដែរអំពីស្ថានភាពបន្ទប់ និងឧបករណ៍ដែលគ្មានអនាម័យ។ នាងបានគិតថា ក្មេងស្រីរកស៊ីផ្លូវភេទជាក់ស្តែងអាចឆ្លងជម្ងឺក្នុងគ្លីនិកបែបនេះ។

៩. (ក្នុងផ្ទះបនលេខ ១៦ ពីមុន) ក្មេងស្រីរកស៊ីផ្លូវភេទទាំងអស់មានមុខស្រដៀងៗគ្នាមកពីតំបន់តំបន់ស្វាយប៉ាក។ មានក្មេងស្រី ១៨នាក់ កំពុងធ្វើការ។ ក្មេងស្រីទាំងអស់សប្បាយចិត្តដោយបានធ្វើការក្នុងក្រុងសៀមរាប ហើយមិនចង់វិលត្រឡប់ទៅធ្វើការក្នុងតំបន់ស្វាយប៉ាកវិញទេ (ពីព្រោះមានករណីមួយក្នុងផ្ទះបនលេខ ២២)។ ម្ចាស់បនប្រុសបានរក្សាសៀវភៅបញ្ជី ដើម្បីឱ្យស្ត្រីរកស៊ីផ្លូវភេទអាចរក្សាបាននូវបញ្ជីពិតប្រាកដនៃភ្ញៀវរបស់គេពោលគឺ ជំរុញឱ្យមានការការពារ ការកេងប្រវ័ញ្ចក្មេងស្រីរកស៊ីផ្លូវភេទដោយម្ចាស់បននោះ។ ម្ចាស់បននោះបាននិយាយថា ការរកស៊ីត្រូវបានផ្សព្វផ្សាយដោយខ្លួនឯងជាកន្លែងម៉ាស្សាតាមពិតទៅមានក្មេងស្រីរកស៊ីផ្លូវភេទ ៣ ឬ៤នាក់ ប៉ុណ្ណោះ ដែលមានសមត្ថភាពក្នុងជំនាញនេះ ដូច្នេះភ្ញៀវភាគច្រើនមកដើម្បីរួមភេទ។ ភ្ញៀវទាំងអស់ក្នុងផ្ទះបននេះប្រើស្រោមអនាម័យ បើប្រៀបធៀបទៅ

នឹងចំនួនតិចតួចណាស់ក្នុងតំបន់ស្វាយប៉ាក។ ទោះបីជាយើងមិនបានសួរថៅកែក៏យើងបានឮពាក្យចចាមអារាមថា កុមាររកស៊ីផ្លូវភេទត្រូវបានលាក់ទុកក្នុងដំបូលអាគារ។

១០. (ផ្ទះបនលេខ ២១ ពីមុន) ហាក់បីដូចជាមានបរិយាកាសស្រស់ស្រាយ។ មានក្មេងស្រីរកស៊ីផ្លូវភេទ ១៥នាក់ ភាគច្រើនមកពីតំបន់ស្វាយប៉ាក។ ក្មេងស្រីទាំងនោះមានញាតិសណ្តានក្នុងតំបន់ស្វាយប៉ាក គេមានបំណងវិលត្រឡប់ទៅចូលរួមបុណ្យចូលឆ្នាំថ្មីនៅវៀតណាមនៅដើមខែកុម្ភៈ ប៉ុន្តែពួកគេទាំងអស់ចង់វិលត្រឡប់មកកាន់សៀមរាបវិញ។ ម្ចាស់បនមានការត្រេកអរខ្លាំងអំពីការប្រើប្រាស់ស្រោម និងការពិនិត្យសុខភាព ចំពោះបុគ្គលិករបស់គាត់ ហើយនៅខណៈពេលពីមុនស្ថិតនៅក្នុងតំបន់ស្វាយប៉ាក គាត់ក៏មានការព្រួយបារម្ភអំពីសុខភាព និងសុវត្ថិភាពនៃបុគ្គលិករបស់គាត់ពោលគឺ រៀបចំអោយមានការធ្វើពិសោធន៍ ជម្ងឺទឹករងៃ។

១១. យើងបានធ្វើសំភាសអតីតក្មេងស្រីរកស៊ីផ្លូវភេទម្នាក់មកពីស្វាយប៉ាក ផ្ទះលេខ១២។ នាងសប្បាយចិត្តណាស់ក្នុងតំបន់ថ្មីរបស់នាង ហើយប្អូនស្រីរបស់នាងក៏ស្នាក់នៅជាមួយនាងដែរ នៅខណៈនោះដែលម្តាយរបស់នាងក៏បានប្តូរមកនៅសៀមរាបដែរ ហើយបានជួលបន្ទប់តូចមួយ។ ក្មេងស្រីរកស៊ីផ្លូវភេទនេះ និងប្អូនស្រីរបស់នាង ឥឡូវនេះកំពុងធ្វើការក្នុងហាងម៉ាស្សាតូក្យូ។ ពេលថ្ងៃពួកនាងស្នាក់នៅជាមួយម្តាយរបស់ពួកនាង។ ការងារចាប់ផ្តើមធ្វើនៅម៉ោង ៤រសៀល ហើយបានបន្តរហូតដល់ទៀបភ្លឺ ដែលវាមានការស្រដៀងគ្នាទៅនឹងម៉ោងធ្វើការនៃហាងដ៏ទៃដែលយើងបានធ្វើសំភាសក្នុងក្រុងសៀមរាប។

១២. នៅថ្ងៃទី១៦ ខែមករា យើងបានធ្វើសំភាសន៍ក្មេងស្រីខ្លះ ដែលអតីតកាលពួកគេធ្វើការក្នុងហាងម៉ាស្សាក្នុងតំបន់ស្វាយប៉ាក ដែលប្តូរមករកការងារធ្វើក្នុងក្រុងសៀមរាប។ ពួកគេបានផ្តល់នូវចម្លើយស្រដៀងៗគ្នាចំពោះអ្នកដទៃដែលយើងបានធ្វើសំភាសន៍ ដោយផ្តោតទៅលើស្ថានភាពការងារកម្រិតជីវភាពរស់នៅមានភាពប្រសើរក្នុងក្រុងសៀមរាប។ យើងក៏បានធ្វើសំភាសន៍សមាជិកសហគមន៍ស្វាយប៉ាកដទៃទៀតផងដែរ ដូចជាអ្នករត់ម៉ូតូឌុប ចុងភៅធម្មតា ចុងភៅក្នុងហាង អ្នកបម្រើតាមផ្ទះ អ្នកលក់នំប៉័ង និងបុគ្គលិកបម្រើហាងកាហ្វេជាដើម ។ល។ ដែលពួកគេបានដូរមកកាន់សៀមរាប ដើម្បីផ្តល់សេវាកម្មជាទាសីសម្រាប់ហេដ្ឋារចនាសម្ព័ន្ធពេស្យាស្ថាន។

១៣. យើងបានត្រួតពិនិត្យភូមិមួយដែលមានចំងាយ ២-៣ គីឡូម៉ែតពីក្រុងសៀមរាប។ មានខារ៉ាអូខេជាច្រើនដែលបុរសក្នុងស្រុកអាចរួមភេទ។ ភូមិមួយដទៃទៀតក្បែរនោះឈ្មោះថា ស្រះស្រង់ (ក្បែរអង្គរវត្ត) មានកុមារជាច្រើនលក់វត្ថុអនុស្សាវរីយ៍អាចផ្តល់ឱកាសដល់ជនអនាចារ។

១៤. យើងក៏បានធ្វើសំភាសន៍ផងដែរក្នុងតំបន់ស្វាយប៉ាក មានក្មេងស្រីម្នាក់មកពីសៀមរាប (ផ្ទះបនពីមុនលេខ ៦) (ផ្ទះបននេះនៅតាមបណ្តោយម៉ាត់ទន្លេមិននៅជិតផ្ទះបនដទៃទៀតទេ)។ ពីមុននាងធ្វើការក្នុងផ្ទះបនស្វាយប៉ាកលេខ ១៥។ នាងបាននិយាយថា នាងចង់វិលត្រឡប់ទៅកាន់ក្រុងសៀមរាបវិញ។

## ព័ត៌មានតាមអ៊ីនធំណេត ស្ដីអំពីប្រទេសកម្ពុជា និងផ្លូវភេទ

1. http://www.penhball.com/html/svay park.html

វាហាក់បីដូចជាគ្មានបញ្ហាលំបាកទេ ដែលអង្គការក្រៅរដ្ឋាភិបាលមានការព្យាយាមបញ្ឈប់តំបន់ស្វាយប៉ាក ពីជំនួញដែលពួកគេតែងតែស្វែងរកវិធីដើម្បីបន្ត។ នៅខណៈពេល ដែលមានការផ្សព្វផ្សាយជាអវិជ្ជមានទាំងអស់ យ៉ាងពិតប្រាកដបានបន្ថយនូវភ្ញៀវទេសចរពួកបច្ចឹមប្រទេសមួយចំនួនដែលធ្វើដំណើរចម្ងាយ ១១ គីឡូម៉ែតពីក្រុង វាហាក់ដូចជាមានក្រុមជនជាតិជប៉ុន និងខ្មែរចូលរួមសកម្មភាពនោះយ៉ាងខ្លាំងក្លាដដែល។ មុនពេលម៉ោងសំខាន់ៗ សម្រាប់ទៅក្នុងតំបន់នោះគឺ នៅពេលរសៀល ប៉ុន្តែឥឡូវនេះមានបុរសភាគច្រើនទៅតំបន់នោះនៅពេលល្ងាច និង ពេលយប់ដែលពីម៉ោង ៨ ទៅម៉ោង ១០ ពេលយប់ហាក់បីដូចជាពេលវេលាដ៏មានប្រជាប្រិយ។ ទោះបីជាឈ្មោះ ទាំងអស់ត្រូវបានរើចេញពីផ្ទះបននោះយ៉ាងណាក៏ដោយ អ្នកពពាយនាយលក់ពាសវាលពាសកាល និងមេបនភាគ ច្រើនសប្បាយចិត្តដោយប្រាប់ភ្ញៀវរបស់គេនូវផ្ទះដែលមានស្រី។

មានផ្លូវថ្មីជាច្រើនលំអរដោយភ្លើងទូរទាំងទីក្រុង។ រង្គសាលម៉ាធីនី បានផ្លាស់ប្ដូរទីតាំងមកនូវក្បែរស្ថាន ទូតចិន ហើយ The Walkabout ក្លាយជាកន្លែងរាត្រីដ៏ក្ដៅគគុគ។ តាមបណ្ដោយផ្លូវលេខ ៦៣ នៅពេលថ្ងៃមាន អ្នកពពាយនាយពាសវាលពាសកាលដ៏ច្រើនអនេកព្យាយាមដឹកនាំអ្នកទៅរកផ្ទះបនពិសេសៗ និងផ្លូវលេខ ១៥៤ ក្បែរផ្លូវនរោត្តមមានផ្ទះបនថ្មីមួយចំនួនកំពុងប្រតិបត្តការ។ ខ្ញុំគិតថា អ្វីៗផ្លាស់ប្ដូរកាន់តែច្រើនពួកគេក៏រកស៊ីដដែលៗ កាន់តែច្រើនប្រទេសកម្ពុជានៅតែជាទិសដៅដ៏មានប្រជាប្រិយភាព ចំពោះអ្នកលេងល្បែងដោយមានអារម្មណ៍ប្រថុយ ប្រថាន។

## ឧបសម្ព័ន្ធទី ២ ៖ តារាងសំណួរ

| | |
|---|---|
| ការបរិច្ឆេទនៃការធ្វើសម្ភាសន៍ | |
| សញ្ជាតិ | |
| ឈ្មោះអ្នកត្រូវបានធ្វើសម្ភាសន៍ | |
| ភេទអ្នកត្រូវបានធ្វើសម្ភាសន៍ | |
| អាយុអ្នកត្រូវបានធ្វើសម្ភាសន៍ | |
| ទីកន្លែងកំណើត | |

| **សំណួរ** | **ពីមុន** | **បច្ចុប្បន្ន** |
|---|---|---|
| ១. តើក្នុងគ្រួសាររបស់អ្នកមានសមាជិក ប៉ុន្មាននាក់ ? | | |
| ☆ ចំនួនមនុស្សពេញវ័យ | | |
| ☆ ចំនួនកុមារ | | |
| ២. តើគ្រួសាររបស់អ្នកមានសមាជិក ប៉ុន្មាននាក់ ដែលកំពុងស្វែងរក ប្រាក់ចំណូល ? | | |
| ៣. ក្រោយពីការបិទតំបន់ស្វាយប៉ាក តើអ្នកបានប្រឈមមុខ នឹងការ ប្រែប្រួលដែរឬទេ ? ☆ ហេតុអ្វី ? | | |
| ៤. ក្រោយពីការបិទតំបន់ស្វាយប៉ាក តើសមាជិកមួយចំនួនក្នុងគ្រួសារអ្នក ត្រូវបានចាកចេញពីផ្ទះដើម្បីស្វែងរក ប្រាក់ចំណូលដែរឬទេ ? ☆ ប្រសិនបើមាន តើប៉ុន្មាន នាក់ និងទៅទីណា ? | | |
| ៥. តើគ្រួសាររបស់អ្នកមានប្រាក់ចំណូល ប៉ុន្មានក្នុងមួយថ្ងៃ ? | | |
| ៦. តើអ្នកចំណាយប៉ុន្មានក្នុងមួយថ្ងៃ ? | | |
| ៧. ចំណាយទៅលើអ្វីខ្លះ ? | | |

| | | |
|---|---|---|
| ៨. តើអ្នកគិតថា ចំណូលរបស់អ្នក ឬ<br>ចំណាយរបស់អ្នកមានការធ្លាក់ចុះឬ ?<br>☆ ហេតុអ្វី ? | | |
| ៩. ប្រសិនបើចំណូលរបស់អ្នកធ្លាក់ចុះ តើអ្នកមាន<br>ដំណោះស្រាយណាមួយ ដើម្បីបង្កើនវាដែរឬទេ ? | | |
| ១០, តើអ្នកមានជំពាក់បំណុលគេឬទេ ?<br>☆ ប្រសិនបើមានប៉ុន្មាន ?<br>☆ ប្រសិនបើមានហេតុអ្វី ? | | |
| ១១. តើអ្នកគិតដូចម្តេចក្រោយពីការបិទ<br>តំបន់ស្វាយប៉ាក ?<br>☆ ហេតុអ្វី ? | | |
| ១២. តើអ្នកធ្លាប់ឃើញជនអនាចារ<br>មកក្នុងភូមិនេះដែរឬទេ ? | | |